អាស័យដ្ឋានថ្មី

ទីក្រុងថ្មី

ភពថ្មី

មកដល់មិត្តសំលាញ់ចាន់ណារិនជាទីនឹករលឹកបំផុត,

គ្នាមិនដឹងត្រូវនិយាយប្រាប់ឯងយ៉ាងដូចម្តេចដំបូង ថាគ្នាពិតជាមានសេចក្តីនឹករលឹកចំពោះពួកម៉ាកនិងមិត្តភក្តិយើងទាំងអស់គ្នា។ គ្នាក៏មានសេចក្តីសោកស្តាយណាស់ដែរ ដែលពួកយើងទាំងអស់គ្នា ពុំអាចបន្តខ្សែជីវិតរួមគ្នាទៅទៀតបាន ហើយគ្នាដឹងយ៉ាងច្បាស់ថាពួកម៉ាកឯងព្រមទាំងអ្នកទាំងអស់គ្នាមានសេចក្តីទុក្ខព្រួយអំពីរឿងដែលបានកើតឡើងកន្លង។

គ្នាសរសេរសំបុត្រមកពួកម៉ាកឯងនេះ ក៏ព្រោះតែគ្នាមិនចង់ឲនៅមានការសោកស្តាយបន្តទៅទៀត ព្រោះអ្វីៗវាត្រូវបានគេកំនត់ទុកទៅហើយ។ ម្យ៉ាងវិញទៀត គ្នាមានបំណងចង់ឲពួកម៉ាកឯងក៏ដូចជាមិត្តភក្តិឯទៀត ដោយនាំគ្នាបើកចិត្តទូលាយ រីករាយ និងស្វាគមន៍នូវអ្វីដែលជាការពិតនិងអ្វីដែលបានកើតមានឡើង។

អ្វីដែលគ្នាចង់ប្រាប់នៅពេលនេះ គឺថាគ្នាសព្វថ្ងៃមានសេចក្តីសុខ មានសេចក្តីសប្បាយ និងមានអ្វីៗគ្រប់បែបយ៉ាងទាំងអស់ហើយគ្នាក៏មិនខ្វល់ខ្វាយពីបញ្ហាទាំងឡាយ ក្នុងជីវិតជាមនុស្សដែរ។ គ្នាឥឡូវនេះ កំពុងតែរស់នៅក្នុងពិភពមួយដ៏ស្ងប់ស្ងាត់ជាទីបំផុត។ គ្នាមានសេចក្តីត្រេកអរជាពន់ពេកដែលត្រូវបានគេអនុញ្ញាតឲគ្នាបានសរសេរសំបុត្រ មកពួកម៉ាកឯងនៅពេលនេះហើយ នៅតាមរយៈសំបុត្រនេះដែរ គ្នាចង់ប្រាប់ពួកម៉ាកឯងក៏ដូចជាមិត្តិភក្តិទាំងអស់ឲបានដឹងពីអ្វីដែលគ្នាបានឆ្លងកាត់នៅក្រោយពីព្រឹត្តិការណ៍ដ៏សោកសៅនេះ។

ពួកម៉ាកឯងដឹងទេ? នៅយប់ថ្ងៃទី១២ខែតុលាឆ្នាំ២០០៣វេលាម៉ោង៨យប់ គ្នាគ្រាន់តែនៅចាំបានថា ក្នុងខួរក្បាលរបស់គ្នាបានទទួលសំលេង

**«ផាំងៗ,,, ផាំងៗ,,,,, ប្រាវៗៗៗ,,,,,, អ៊ូយៗៗៗៗ»**

នៅក្រោយពីសំលេងនេះបានរលត់ទៅ ស្រាប់តែគ្នាហាក់បានភ្ញាក់ដឹងខ្លួន វាហាក់បីដូចជា

ក្នាភ្ញាក់ពីដំណេក។ ក្នាងើបឈរដោយយកបាតដៃមកញីមុខនិងភ្នែក ហើយពិសេសទៀតនោះក្នាបានពត់ខ្លួនកាច់ចង្កេះឆ្វេងស្ដាំ។ ក្នាធ្វើចលនាកដោយបង្វិលវាមួយជុំដូចជាទំលាប់ធម្មតារបស់ក្នានៅពេលព្រឹក។ ពេលដែលក្នាកំពុងតែពត់ដៃជើងនោះ ក្នានៅពុំទាន់បើកភ្នែកនៅឡើយទេ តែក្នាហាក់ដូចជាមានអារម្មណ៍នៅក្នុងចិត្តថា តើយប់មិញក្នាបានធ្វើអ្វីខ្លះបានជាក្នាគេងមិនបានប្ដូរសំលៀកបំពាក់ដូចនេះ។ ក្នាពាក់ខោខ្មៅនិងអាវដៃខ្លីពណ៌ក្រហម។

នៅពេលដែលកំពុងតែឆ្ងល់នោះ ក្នាបានបើកភ្នែកសន្សឹមៗ ដោយមិនសូវជាយកចិត្តទុកដាក់អ្វីឡើយ។ ស្រាប់តែពេលនោះក្នាមានការចំលែកយ៉ាងខ្លាំងព្រោះតែក្នាបានដឹងខ្លួនថាក្នាកំពុងតែនៅចំចំនុចកណ្ដាលនៃផ្ទាំងវីដេអូដ៏ធំៗពីរ។មួយផ្ទាំងខាងឆ្វេងដៃរបស់ក្នាមានពណ៌ស ឯម្ខាងទៀតមានពណ៌ក្រហមក្រមៅ។ ក្នាបានដើរទៅជិតផ្ទាំង សំពត់ពណ៌ក្រហមដោយមិនមានការប្រុងប្រយ័ត្ន។ កាលដែលក្នាបានមកដល់ជិតហើយ ក្នាក៏តាំងចាប់ផ្ដើមមើលទៅលើផ្ទាំងចំលែកនោះ ក្នាបានឃើញមនុស្សម្នាជាច្រើននាក់ កំពុងតែប្រមូលផ្ដុំក្នាមើលស្អីគេមិនដឹង។ បើតាមក្នាស្មាននៅក្នុងចិត្តនៅពេលនោះ គឺប្រហែលជាមនុស្សទាំងនេះគេទៅមើលកុន ឬមួយក៏ចូលរួមនៅក្នុងកម្មវិធីពិភពតន្ត្រី ឬក៏ប្រហែលអ្នកនយោបាយ យកអំណោយមកចែកមិនខានបានជាពួកគេមកប្រជ្រៀតក្នាយ៉ាងនេះ។ កំពុងតែគិតពិចារណាទាំងស្រពេចស្រពិល និងខំប្រឹងមើលហ្វូងមនុស្សទាំងនោះនៅលើផ្ទាំងសំពត់ ស្រាប់តែក្នាបានឃើញរថយន្តប៉ូលីសមួយបានបើកមកដល់។ ពួកក្រុមប៉ូលីសនេះមិនសូវជាមានសុជីវធម៌ប៉ុន្មានទេ ដូចជាពួកម៉ាកឯងបានដឹងហើយ គ្រាន់តែពួកគេមកដល់ភ្លាម ក្រុមនេះបានរុញនិងច្រានទៅដល់ ហ្វូងមនុស្សហើយនិយាយខ្លាំងៗឡើងថា៖

«ចេញ...។។។។។!»

ហ្វូងមនុស្សបានងាកចេញដោយទុកផ្លូវឲក្រុមប៉ូលីសនេះ។ ពេលដែលក្នាបានឃើញដូចនេះនៅពីចំងាយ ក្នាពេបមាត់ហើយនឹកនៅក្នុងចិត្តថា៖

«អ្ហើយអាក្អូន! បានតែឯងមានបុណ្យស័ក្ដិបន្តិចបន្តួចហ្នឹង មើលមកអ្នកទន់ខ្សោយដូចជាមិនដល់ខ្លួន»





ក្នាបាននឹកនៅក្នុងចិត្តទៀតថា៖

**«ចុះបើគេគ្រាន់តែមកបើកអំណោយ ម្ដេចក៏មកឃាត់គេដែរ? ហ៊ឹមឃាប់ណាស់ខ្មែរយើង!»**

ក្នាខំគិតនៅក្នុងចិត្តបណ្ដើ ហើយប្រឹងបើកភ្នែកប្រឹមៗសំលឹងមើលទៅទិដ្ឋភាពខាងក្នុងនោះបណ្ដើរ តែក្នាហាក់មើលអ្វីមិនឃើញទាល់តែសោះក្រៅអំពីហ្វូងមនុស្សដ៏កកកុញ ដោយក្នាមិនបានឃើញអ្វីដែលកំពុងកើតឡើងនៅចំកណ្ដាលនៃហ្វូងមនុស្ស។

ក្នាហាក់មានអារម្មណ៍ផងដែរថា ក្នាបើកភ្នែកមិនចង់រួចទេ ហាក់បីដូចជាមានអ្វីមួយមកចាប់បន្តឹងតចឹង តែក្នានៅតែប្រឹងសំលឹងបន្ត។ នៅរំពេចបន្ទាប់ ស្រាប់តែក្នាបានឃើញឡានពេទ្យបានចូលមកដល់និងមានក្រុមជួយសង្គ្រោះចុះពីលើឡានពីរបីនាក់យ៉ាងប្រញាប់។ ដោយសារការជួយវែកផ្លូវពីក្រុមប៉ូលីសនោះហើយ ទើបពួកអ្នកជួយសង្គ្រោះ បានចូលទៅដល់កណ្ដាលហ្វូងមនុស្សនោះបាន។ពួកគេទាំងនេះពិតជារហ័សដៃជើងល្អណាស់។ ពួកគេបានទាញយកគ្រែសែងម្យ៉ាងដែលគេប្រើសំរាប់លើកមនុស្ស ចេញពីក្នុងរថយន្តរបស់គេ ហើយបានសែងទៅលើកបុរសម្នាក់ដែលកំពុងតែដេកនៅលើទ្រូងផ្លូវ។ នៅពេលដែលហ្វូងមនុស្សបានឃ្លាតចេញពីក្នាទើបក្នា បានឃើញច្បាស់ថានៅខាងក្នុងហ្វូង មានមនុស្សពីរនាក់កំពុងតែដេកសន្លប់នៅលើថ្នល់។

អ្នករបួសទីមួយត្រូវបានលើកដាក់គ្រែសែង ហើយនៅពេលដែលអ្នករបួសផ្ងារមុខ ទើប ក្នាបានដឹងថាគេនោះគឺជាពួកម៉ាករបស់យើង **សារ៉េត ! មែន!ពិតជាសារ៉េត!**

ក្នាភ័យណាស់ក្នាខំស្រែកហៅ«**សារ៉េត!,,,,សារ៉េត!**» ក្នាហៅម្ដងហើយម្ដងទៀតតែគេមិនបានឆ្លើយមកក្នាសោះ។ ក្នានៅតែបន្តហៅតែគេនៅតែមិនឆ្លើយ ហាក់បីដូចជា សារ៉េត មិនបានលឺសំលេងរបស់ក្នា។ ក្នាអាចស្មាននៅពេលនោះបានថាសារ៉េត កំពុងតែដេកសន្លប់មិនដឹងខ្លួនហើយអ្វីដែលឲក្នាកាន់តែស្លុតទៀតនោះ នៅត្រង់ថាខ្លួនប្រាណរបស់សារ៉េត ប្រលាក់សុទ្ធតែឈាម។ពេលនោះហើយដែលក្នាកាន់តែឆ្ងល់និងកាន់តែបារម្ភអំពីសារ៉េត។ ក្នាបានរត់ដេញតាមមើលអ្នកក្រុមជួយសង្គ្រោះទាំងនោះដោយស្រែកសួរគេថា៖

**«បងៗតើមានរឿងអ្វី?»**

ទោះបីជាក្នាស្រែកសួរពួកគេមួយផងជាពីរផង តែគ្មានអ្នកណាមួយឆ្លើយមកក្នាវិញឡើយ។

ក្រោយពីក្រុមនេះបានលើកសារ៉េតដាក់ចូលទៅក្នុងរថយន្តរួចហើយ ទើបពួកគេមកយក អ្នករបួសទីពីរដែលកំពុងតែដេកនៅលើថ្នល់នៅឡើយ។ កែវភ្នែករបស់ខ្លាបានមើលទៅតាមដំណើររបស់ក្រុមជួយសង្គ្រោះ។ ពួកគេដែលមានគ្នាបួននាក់ដោយម្នាក់ៗមានទាំងស្រោមដៃផងនោះបានលើកអ្នករបួសទីពីរ ដែលកំពុងតែដេកផ្កាប់នៅនិងថ្នល់។ ពេលដែលក្រុមសង្គ្រោះចាប់ផ្ដើមផ្ងារមុខរបស់គេ ខ្លាសំលឹងទាំងហារមាត់ ហើយខ្លាហាក់មានអារម្មណ៍ថា អ្នករបួសនោះគ្នាដូចជាធ្លាប់ស្គាល់ នៅទីណាមួយ។ ខ្លាបានគិតថាប្រហែលជាមិត្តភក្ដិដែលពួកយើងធ្លាប់បានដើរលេងជាមួយគ្នាពីមុន។ ខ្លាមើលគេសែងបុរសនោះបណ្ដើរ ខ្លាធ្វើកងេកកង់បណ្ដើរដោយខំរំពៃរកនឹកពីឈ្មោះបុរសនោះ។

ខំប្រមូលអារម្មណ៍យកមកគិត ថាពេលណា? កន្លែងណាដែលខ្លាបានស្គាល់បុរសនោះ? នៅពេលដែលខ្លាកាន់តែគិត ខួរក្បាលកាន់តែឲគ្នារកចាំអ្វីមិនឃើញទាល់តែសោះ។ ខ្លាបានផ្ទៀងកមើលតាមតែទិដ្ឋភាពក្នុងសំពត់ក្រណាត់ធំពណ៌ក្រហមក្រមៅនោះ ដែលបាន បង្ហាញរូបភាពមកខ្លា វាហាក់បីដូចជាផ្ទាំងភាពយន្តមួយផ្ទាំង។ ខ្លាមើលរហូតដល់បុរសនោះ ត្រូវបានគេលើកដាក់ទៅក្នុងឡានពេទ្យ ហើយក្រោយមកបន្តិច អ្នករបួសទាំងពីរត្រូវបានគេ ដឹកចេញពីហ្វូងមនុស្សនោះទៅ។

កាលនោះខ្លាពិតជាមានការភិតភ័យជាខ្លាំងនៅពេលដែលបានឃើញសារ៉េតស្ថិតនៅក្នុងសភាពបែបនេះ។ ខ្លាបានទាញទូរស័ព្ទហើយរៀវរកលេខដើម្បីហៅទៅប្រាប់វាសនាដែលជាភរិយារបស់គេ។ កំពុងតែអានចុចរៀវរកលេខស្រាប់តែរំពេចនោះនៅឯខាងឆ្វេងដៃដែលមាន ផ្ទាំងសំពត់សវិញ ស្រាប់តែខ្លាបានឃើញមនុស្សស្រីពីរនាក់កំពុងដើរសំដៅមករកខ្លា សន្សឹមៗក្នុងខណៈពេលដែលខ្លាកំពុងតែអានឈ្មោកទៅលើទូរស័ព្ទ។ ខ្លាបានងើបមើលមុខអ្នកទាំងពីរយ៉ាងភ្ញាហាន ដោយដៃនៅកាន់ប្រុងនិងចុចលេខហៅទៅប្រពន្ធសារ៉េតផង។ ខ្លាសំលឹងទៅ ពួកនាងហាក់បីដូចជាធ្លាប់ស្គាល់ហើយបានពោលឡើងថា៖

**«មកម្ដេចមិនប្រាប់! ធ្វើឲខ្ញុំស្ទើរតែលស់ព្រលឹង ទៅហើយ!»**

អ្នកទាំងពីរមិនកំរើកហើយឆ្លើយតបមកវិញថា៖

**«ពួកខ្ញុំទើបតែដឹងថាលោកប្រុសអញ្ជើញមកដល់»**





ខ្លាសំលឹងទៅមើលពួកគេទាំងពីរដោយចំលែកក្នុងចិត្ត នៅពេលដែលឃើញពួកគេស្លៀកសំលៀកបំពាក់ជារ៉ូប និងទទូរក្បាលដោយស្បៃស្ដើងៗពណ៌សស្គុស ពិសេសនៅពេលដែលពួកនាងហៅខ្លាថាលោកប្រុសនោះ។ យ៉ាងណាក៏ដោយ ខ្លាបាននិយាយបន្តទៀតទាំងញញឹម៖

**«កុំហៅខ្ញុំលោកប្រុសធ្វើអ្វី ហៅខ្ញុំថាកាទៅ ឬបងកាក៏បានដែរ»**

ពួកនាងញញឹមទាំងយកដៃមកខ្ទប់មាត់ ហាក់ទទួលការយល់ព្រមសំណើររបស់ ខ្លា។ ឆ្លៀតពេលនោះ ខ្លាបានក្រលេកមកទូរស័ព្ទវិញ ហើយជាពេលដែលខ្លាឃើញលេខទាក់ទងរបស់ វាសនាល្អម។ ខ្លាចាប់ផ្ដើមហៅភ្លាម តែលេខម្ខាងទៀតមិនព្រមទទួលសោះ។ នៅពេលនោះនាងម្នាក់នៅខាងឆ្វេងដៃហាក់ដឹងថា ខ្លាមិនអាចទាក់ទងបាន ហើយនាងបានពោលឡើងថា៖

**«បងកាមិនអាចទូរស័ព្ទបានទេនៅទីនេះ!»**

**«អត់បានយ៉ាងម៉េចបើខ្ញុំទើបតែបញ្ចូលទឹកប្រាក់១០ដុល្លាកាលពីម្សិលមិញហ្នឹង»**

ខ្លាតបទាំងបើកភ្នែកឆ្ងល់ នាងខាងស្ដាំបានងាកទៅមើលនាងខាងឆ្វេងហើយបែរជានិយាយមកខ្លាវិញថា៖

**«មិនមែនទេបង តាមពិតទៅនៅទីនេះមិនមានប្រព័ន្ធទាក់ទងនោះទេ»**

ពេលដែលនាងនិយាយចប់ខ្លាបើកភ្នែកធំៗ ដោយមិនជឿសំដីនាងទេ ហើយ ខ្លាបាននឹកនៅ ក្នុងចិត្តថា៖

**«អត់ប្រព័ន្ធយ៉ាងម៉េចទៅកើតបើក្រុមហ៊ុនម៉ូប៊ីតែលទើបបានប្រកាសថ្មីៗថាបានតំឡើងអង់តែនពេញផ្ទៃប្រទេសនោះទៅហើយ»**

ខ្លាគិតបណ្ដើរខ្លាសំលឹងទៅមើលទូរស័ព្ទបណ្ដើរ ឯនាងទាំងពីរទៅជា ញញឹមញញែមដាក់ខ្លាញញឹមបែបអស់សំណើចនិងរឿងអ្វីមួយចំលែក។ ពេលដែលខ្លា សំលឹង មកនាង ទើបនាងឈប់ញញឹមហើយបែរជានាំគ្នានៅស្ងៀមវិញ។

ដោយបញ្ហាទូរស័ព្ទមិនដើរដូចនេះ ខ្លាក៏បានងាកមករកផ្ទាំងសំពត់ពណ៌ក្រហមដែលនៅខាងឆ្វេងដៃនោះវិញ តែពេលនេះរូបភាព ហ្វូងមនុស្សទាំងនោះត្រូវបានរលាយអស់ទៅហើយ។ ខ្លាខំរកមើល តែវាគ្មានអ្វីទាំងអស់ក្រៅពីរូបភាពពណ៌សស្គុស និងនាងទាំងពីរនៅជុំវិញខ្លា

នោះ។ គ្នាខំយកដៃមកញីភ្នែកជាញយផងហើយខំប្រឹងសំលឹងរកមើលម្តងទៀត តែនៅតែរកអ្វីមិនឃើញសោះ។ ឃើញគ្នាមានសភាពង៉េមង៉ាមដូចនេះ នាងទាំងពីរ បានមើលមុខគ្នាសារ ជាថ្មី ហើយម្នាក់នៅខាងស្តាំដៃបានពោលឡើងថា៖

«បងកាកុំខ្វល់ខ្វាយឲសោះ អ្វីៗដែលបងបានមើលឃើញអំបាញ់មិញនេះវាគ្រាន់តែជាការស្រមៃមមើមមាយតែប៉ុណ្ណោះ»

«ការស្រមៃ!» គ្នាលាន់មាត់បែបឆ្ងល់

«មែនហើយគឺការស្រមៃ» នាងទាំងពីរបានឆ្លើយព្រមគ្នា។

«ចុះពួកនាងមកពីណា? ហើយហេតុអ្វីបានជាស្គាល់ខ្ញុំច្បាស់ម្ល៉េះ?»

«ពួកខ្ញុំទាំងពីរបានកើតចេញពីផលបុណ្យរបស់បង ហើយមានតួនាទីមកមើលថែរក្សាបង ពួកខ្ញុំរង់ចាំបងនៅទីនេះអស់រយៈពេលយូរណាស់មកហើយ»

គ្នាបើកភ្នែកហើយកាន់តែឆ្ងល់នូវអ្វីដែលនាងនិយាយ៖

«ផលបុណ្យអ្វីទៅ?»

«អំពើល្អដែលបងបានសាង»

គ្នាពេបមាត់តិចៗហាក់មិនជឿទាល់តែសោះនូវអ្វីដែលនាងកំពុងតែប្រាប់នេះ។

«ចុះពួកនាងឈ្មោះអ្វីដែរ?»

«ខ្ញុំឈ្មោះបុទម ឯបងស្រីឈ្មោះវត្តី តើបងពិតជាមិនបានចាំអ្វីសោះពីពួកយើងមែនទេ?» នាងខាងឆ្វេងឆ្លើយបែបឆ្ងល់

នៅពេលដែលនាងព្យាយាមពន្យល់គ្នា កាលនោះគ្នាពិតជាមិនយល់អ្វីទាំងអស់ ហើយ គ្នាបានគិតនៅក្នុងចិត្តថា នេះប្រហែលជាការយល់សប្តិមួយតែប៉ុណ្ណោះមើលទៅ។ គ្នាយកដៃមកអេះក្បាលដោយបន្តការគិតពិចារណា តែពេលនោះនាងខាងស្តាំបាននិយាយថា៖

«សូមបងកុំបារម្ភ បន្តិចទៀតបងនឹងចងចាំរឿងទាំងឡាយមិនខាន»

«តោះបងយើងដល់វេលាទៅហើយ!» កញ្ញាដ៏ស្រស់ស្អាតទាំងពីរបានពោលឡើង

«ដល់ម៉ោងទៅណា?»

«ដល់ម៉ោងដែលពួកយើង ត្រូវជូនបងទៅកន្លែងដែលបងមិនដែលស្គាល់ ជាកន្លែងដែល





សប្បាយហើយមិនខ្វាយខ្វល់ពីទុក្ខសោកទាំងឡាយ» នាងខាងឆ្វេង(បុទម)

ចាន់ណារិនឯងដឹងទេ? នៅពេលដែលពួកនាងនិយាយម្តងៗ ហាក់បីដូចជានាងកំពុងតែសំដែងខ្សែរភាពយន្តដាក់គ្នាឥចឹង។ កាយវិការនិងពាក្យសំដីដ៏ទន់ភ្លន់របស់នាងទាំងពីរ ធ្វើឲគ្នានឹកស្មានមិនដល់ទាល់តែសោះ។

វត្តីបានហុចដៃដ៏ស្រលូនរបស់នាងទាំងស្នាមញញឹមសំដៅមកគ្នាហើយនិយាយខ្សឹបៗឡើងថា៖

«ហុចដៃមកបង ពួកយើងទៅទាំងអស់គ្នា»

គ្នានៅអេះអុញបន្តិច តែយ៉ាងណាក៏ដោយ គ្នាបានហុចដៃទៅនាង។ ពិតណាស់ចាន់ណារិនអើយ ដៃនាងពិតជាត្រជាក់ដែលធ្វើឲអារម្មណ៍របស់គ្នាបានភ្លេចរឿងអ្វីទាំងអស់។ គ្នាហាក់បីដូចជានៅលើកំពូលភ្នំទឹកកកមួយដែលនៅទីនោះបានស្អំមកលើខ្លួនប្រាណគ្នាឲមានសេចក្តីសុខ ភ្លេចអស់ហើយនូវការឈឺចាប់ ការនឿយហត់ និងការគិតទាំងប៉ុន្មាន។ គ្នាព្រមទាំងនាងទាំងពីរបានបណ្តែតខ្លួន នៅលើលំហរអាកាសម្យ៉ាងដែលមានពណ៌សក្បុស យ៉ាងសន្សឹមៗ។ មានខ្យល់ជំនោរបានបក់រវិចៗ មកប៉ះនិងមុខមាត់របស់គ្នា ហើយនៅពេលដែលគ្នាក្រលេកទៅលើឬទៅក្រោម ទៅមុខទៅក្រោយ គ្នាមិនឃើញអ្វីទាំងអស់ក្រៅអំពីពិភពពណ៌សដ៏ស្រទន់ដែលកំពុងតែបក់រវិចៗ។ វាមិនខុសពីពណ៌របស់បុទមវត្តីទេ ដោយសារតែ សំលៀកបំពាក់បានបំបាំងខ្លួនប្រាណ គ្នាបានត្រឹមតែឃើញផ្ទៃមុខនាងទាំងពីរតែប៉ុណ្ណោះ។ ផ្ទៃមុខដែលស្រស់ស្អាតដូចជាទេវតា។

ពួកយើងបានបន្តបណ្តែតខ្លួនរហូតមកដល់កន្លែងមួយដែលផុតពីផ្ទៃពណ៌ស។ នៅទីនោះពិតជាកន្លែងដ៏ធំល្វឹងល្វើយ។ ជាកន្លែងដែលមិនមានពណ៌សទៀតទេ។ វាត្រូវបានជំនួសដោយពណ៌គ្រប់ប្រភេទ ជាពណ៌ដែលឆើតឆាយស្រស់បំព្រង។

នៅជុំវិញខ្លួនរបស់គ្នានៅពេលនោះ ហាក់ទទួលបាននូវក្លិនដ៏ក្រអូបឈ្ងុយឈ្ងប់ ហាក់បីដូចជាទឹកអប់ ដែលបានមកពីឋានតុសិត។ នៅក្នុងមណ្ឌលដ៏ធំមួយ គ្នាបានសង្កេតពីចំងាយឃើញមានមនុស្សម្នាជាច្រើនរាប់រយនាក់កំពុងតែធ្វើដំណើរទៅមក ពួកគេទាំងនោះហាក់បី

ដូចជារង់ចាំធ្វើដំណើរទៅទីណាមួយមិនដឹង។ ក្នុងចំណោមពួកគេ មានទាំងប្រុសទាំងស្រី ហើយម្នាក់ៗសុទ្ធតែមានអ្នកហែរហមដូចជាគ្នាដែរ។ អ្វីដែល គ្នាចាប់អារម្មណ៍ជាងគេ មុនពេលដែលគ្នាបោះជើងចូលទៅមណ្ឌលនោះ គឺនៅត្រង់ថា ឃើញពួកគេទាំងនោះ ហាក់បីដូចជា មិនមាត់មិនកអ្វីទាំងអស់។ពួកគេគិតតែពីដើរទៅដើរមកដោយសភាពស្ងៀមស្ងាត់បំផុត។

បន្ទាប់ពីបានឃើញសភាពទាំងនេះពីចំងាយ គ្នាដែលក្នុងខណៈពេលនោះនៅឈរពីមុខបុទមវត្តី បានងាកមករកនាងទាំងពីរដោយថ្នមៗ។ អ្នកទាំងពីរញញឹមមករកគ្នា ហើយវត្តីបានលាបាតដៃជាសញ្ញាឲគ្នាទំលាក់ជើងចូលទៅក្នុងមណ្ឌលនោះ។គ្នាបានធ្វើតាមនាងដោយដើរចុះកាំជណ្ដើរបន្តិចម្ដងៗរហូតគ្នាមានអារម្មណ៍ថា គ្នាបានមកដល់សិប់ក្នុង មណ្ឌលដ៏ចំលែកនេះហើយ។ ដំបូង គ្នាពិត ជាមានអារម្មណ៍ខ្លាចបន្តិចដែរ នៅពេលដែលបានឃើញមណ្ឌលនេះពីចំងាយ ក៏ប៉ុន្តែនៅពេលដែលបានដាក់ខ្លួនមកដល់ហើយ តាមពិតទៅវាមានសំលេងអ៊ូអរហាក់បីដូចជានៅព្រលានយន្តហោះឥចឹង។ នៅពេលនោះហើយ ដែលគ្នាឈប់ភ័យខ្លាចហើយ បន្តដើរទៅមុខទៀតដោយបុទមវត្តីនៅដើរតាមក្រោយ។ គ្នាដើរបណ្ដើរ គ្នាក្រលេកមើលឆ្វេងស្ដាំបណ្ដើរ។គ្នាបានឃើញមនុស្សម្នាជាច្រើន បាននិងកំពុងនិយាយគ្នាមិនដាច់ពីមាត់ ហើយពួកគេហាក់បីដូចជាប្រញាប់និងចេញដំណើរណាស់។ គ្នានៅតែឆ្ងល់តែមិនបានសួរទេ ព្រោះតាមធម្មតានៅពេលដែលយើងទៅណាមកណាគឺត្រូវតែយកឥវ៉ាន់តាមខ្លួន ចុះពួកគេវិញម្ដេចក៏គ្មានអ្នកណាយកអ្វីសោះឥចឹង? គ្នាគិតបណ្ដើរហើយបន្តដំណើរមកមុខបណ្ដើរ។

ដើរបានហួសបន្តិចគ្នាបានឃើញហាងលក់គ្រឿងអលង្ការមួយ គ្នាបានចូលទៅក្នុងហាង។ នៅទីនោះពិតជាមានរបស់របរ មាសប្រាក់ត្បូងពេជ្រដ៏ល្អ ហើយនៅពេលដែល គ្នាក្រលេកទៅមើលអ្នកលក់ ពួកគេដែលមានគ្នាប្រាំនាក់សុទ្ធជានារីនោះ បានសំពះជំរាបសួរគ្នាពីចំងាយដោយសេចក្ដីស្វាគមន៍។ គ្នាក៏បានអោនគោរពទៅពួកគេវិញដែរ។ អ្នកលក់ទាំងអស់សុទ្ធតែស្លៀកពាក់ដូចជាបុទមវត្តីដែរ។ គ្នាបានចាប់ផ្ដើមមើល ពីទូដាក់ចិញ្ចៀនពីមួយទៅមួយ រហូតដល់ទូមួយដែលមានចិញ្ចៀនសុទ្ធតែដាំគ្រាប់ពេជ្រល្អភ្លឺចិញ្ចាច។ នៅទីនោះគ្នាបានសំលឹងឃើញកូនចិញ្ចៀនដ៏តូចច្រលឹងមួយដែលមានដាំគ្រាប់ពេជ្រនៅពីលើ។ គ្នាបានយកដៃទៅលទល់និងទូនោះដើម្បីអាចដឹងពីទំហំរបស់វា។ តាមការស្មានរបស់គ្នា ចិញ្ចៀននោះប្រកដជា ត្រូវដៃ





ដានិតគូរដណ្ដឹងរបស់គ្នាដែលពួកយើងនឹងត្រូវរៀបការជាមួយគ្នាក្នុងពេលឆាប់ៗនេះមិនខាន។ គ្នាពិតជាស្រលាញ់ចិញ្ចៀននោះណាស់នៅពេលដែលបានឃើញ។ គ្នាបានគិតនៅ ក្នុងចិត្តថាត្រូវតែទិញ ទោះបើថ្លៃយ៉ាងណាក៏ដោយ ព្រោះតែ គ្នាចង់យកទៅបំពាក់ឲដានិតនៅ ថ្ងៃភ្ជាប់ពាក្យខាងមុខនេះ។

គ្នាប្រាប់ចាន់ណារិនឯងតាមត្រង់ ចិញ្ចៀននោះវាពិតជាស្អាត វាមានពណ៌ភ្លែកៗ ពណ៌របស់វាបានបាញ់មកលើភ្នែកព្រៀកៗ។ ជាចិញ្ចៀនម្យ៉ាងដ៏ប្រណិតដែល គ្នាមិនដែលបានឃើញកាលពីមុន។ គ្នាចំណាំទូដាក់ចិញ្ចៀននោះតែ គ្នាមិនទិញឬសួរអ្នកលក់ភ្លាមនោះទេ។ គ្នាបន្តដើរទៅមើលទូដាក់គ្រឿងអលង្ការដទៃទៀត។

អូពុទ្ធោអើយ! វាជាលើកទីមួយហើយដែលគ្នាបានឃើញហាងដ៏ធំដែលលក់តែរបស់របរស្អាតៗ និងគ្រប់ប្រភេទ។ វាមានតាំងពីខ្សែរកខ្សែរដៃ កងជើង ក្រវិល និងរបស់ផ្សេងៗឯទៀតដែល ធ្វើឡើងដាំទៅដោយគ្រាប់ពេជ្រ។

គ្នាបានដើរមួយជុំវិញហាង ទើបគ្នាសសៀរទៅកាន់អ្នកលក់ ហើយធ្វើជាសួរដោយចង្អុលទៅរបស់ផ្សេងថា៖

«ខ្សែរកមួយនោះថ្លៃប៉ុន្មានដែរ?»

«១០ផលបុណ្យ លោកប្រុស» អ្នកលក់ឆ្លើយ

«ថាម៉េចនៅស្រុកនេះ គេអត់ចាយដុល្លាទេអី?» គ្នាសួរបែបឆ្ងល់

ពួកនាងគ្រវីក្បាលដោយចង់ប្រាប់ថាមិនទទួលទេហើយគ្នាក៏បានសួរបន្តទៅទៀតថា៖

«ចុះបើខ្ញុំមានតែដុល្លាគិតយ៉ាងម៉េចទៅ?»

គ្រាន់តែគ្នានិយាយចប់ភ្លាមស្រាប់តែ បុទមបានមកជិតគ្នាតែម្ដងហើយខ្សឹបមកប្រាប់គ្នាថា៖

«ជាមួយនិងបាតដៃរបស់បង បងអាចទិញអ្វីក៏បានដែរ»

គ្នាមើលទៅបុទមឯវត្តីនាងបានងក់ក្បាលយល់ព្រម ដូចនេះគ្នាបានបន្តសួរទៅអ្នកលក់ទៀតថា៖

«តើពិតមែនទេដែលខ្ញុំអាចបងលុយដោយប្រើបាតដៃរបស់ខ្ញុំ?»

អ្នកលក់ញញឹមទទួលស្គាល់ថាវាជាការពិត។នៅពេលនោះគ្នាពិតជាចំលែកក្នុងខ្លួនមែនទែនតែគ្នាក៏សប្បាយចិត្តណាស់ដែរនៅពេលបានដឹងដូចនេះ។ គ្នាបានសំរេចចិត្តទិញខ្សែរកមួយខ្សែរព្រមជាមួយចិញ្ចៀនពេជ្រនោះសំរាប់ទុកឱ្យជានិត ហើយគ្នាក៏បានធ្វើជាកាដូផងដែរនូវខ្សែរកម្នាក់មួយខ្សែរសំរាប់បុទមវត្តីតែពួកនាងមិនព្រមទទួលទាល់តែសោះ ទោះបីជា គ្នាបានអង្វរពួកនាងយ៉ាងណាក៏ដោយ។

ពួកនាងគ្រាន់តែនិយាយថា ពួកនាងសប្បាយចិត្តណាស់ទៅហើយដែលបានមកនៅបំរើ គ្នានៅទីនេះ។

ពួកម៉ាកឯងដឹងទេ? នៅពេលដែល គ្នាបង់លុយ វាហាក់បីដូចជាគួរឱ្យអស់សំណើចណាស់។ គេបានយកម៉ាស៊ីនម្យ៉ាងដែលមានទំហំដូចជាម្រៀមដៃ ហើយគេឱ្យ គ្នាដាក់បាតដៃនៅលើម៉ាស៊ីននោះ។ គ្នាបានធ្វើតាមគេ ហើយនៅពេលដែលម៉ាស៊ីនទទួលបាតដៃ និងមានចេញពន្លឺភ្លើងពណ៌ខៀវចេញពីម៉ាស៊ីន ទើបអ្នកលក់ប្រាប់ឱ្យ គ្នាដកដៃចេញមកវិញ។ គ្នាបានដកដៃចេញដោយទទួលគ្រឿង អលង្ការនៅដៃម្ខាងទៀត។

ពួកយើងទាំងបីនាក់បានដើរចេញពីហាងនោះ ហើយពួកយើងបានដើរកាត់ភោជនីយដ្ឋានមួយដែលនៅជិតនោះដែរ។គ្នាបានក្រលេកមកក្រោយហើយសួរទៅបុទមវត្តីក្រែងលោពួកនាងឃ្លាន។ ពួកនាងមិនឆ្លើយក្រៅពីគ្រវីក្បាលដោយចង់បញ្ជាក់ថាពួកនាងមិនចង់ចូលនោះទេ។ គ្នាញ៉ិចស្មាបន្តិចហើយក៏បន្តដើរទៅមុខទៀត។ គ្នាដើរបណ្តើរ នៅតែសំលឹងមើលទៅទិដ្ឋភាពនៅជុំវិញខ្លួនបណ្តើរគឺនៅតែមានមនុស្សទៅមកមិនចេះដាច់នៅតាមផ្លូវជាប្រចាំ។

គ្នាបានដើរមកដល់បន្ទប់ដ៏ធំមួយហើយបានចូលទៅខាងក្នុង។ នៅទីនោះ គ្នាបានឃើញមនុស្សម្នាកំពុងតែលេងល្បែងស៊ីសង អ្នកខ្លះកំពុងលេងបៀ អ្នកខ្លះទៀតលេងអុក ហើយក៏មានអ្នកដែលកំពុងតែផឹកស្រានោះដែរ។ នៅក្នុងបន្ទប់នោះ ម្នាក់ៗបានលេងល្បែងផ្សេងៗពីគ្នាទៅតាមអ្វីដែលគេចូលចិត្ត។ គ្នាគ្រាន់តែឈរមើលមួយសន្ទុះ វាបានធ្វើឱ្យ គ្នាស្ទើរតែវិលមុខ ទើបគ្នាបានចេញពីបន្ទប់នោះមកវិញ។ចេញមកខាងក្រៅផ្លូវដើរវិញ។

គ្នាបានបន្តដើរជាមួយកញ្ញាដ៏ស្រស់ស្អាតទាំងពីរទៀត ដែលនៅឈរខាងក្រោយខ្នងរបស់គ្នា។ មកដល់មុខបន្តិច មានបន្ទប់មួយដែលមានផ្លាកដាក់ថា៖





«ឌីសស្កូ»

គ្នាភ្ញាក់ព្រើតដោយមិននឹកស្មានថានៅទីនេះក៏មានឌីសស្កូដែរ។ គ្នាបានក្រលេកមកខាងក្រោយហើយសួរអ្នកទាំងពីរថា៖

**«ម៉េចចង់ចូលទេ?»**

ពួកនាងមិនឆ្លើយគ្រាន់តែញញឹមគ្រវីក្បាលដោយហួសចិត្តថាមិនសមនឹងចង់ចូលទីនេះសោះ។ ពួកនាងក្រញៀងស្មាហើយវត្តីបាននិយាយតបមកវិញថា៖

**«ស្រេចតែបងទេ បើបងចង់ចូល អូនចូលបានតើ»**

ឃើញសញ្ញាភ្លើងខៀវដូចនេះ គ្នាក៏បាននិយាយទៅកាន់នាងទាំងពីរថែមទៀតថា៖

**«តោះចូលលេងបន្តិចសិនទៅ ចង់ដឹងថាតើទីនេះមានអ្វីខ្លះអស្ចារ្យ?»**

បុទមវត្តីបានងក់ក្បាលហើយពួកយើងទាំងបីបានបណ្តើរគ្នាចូលទៅក្នុងក្លិបកំសាន្តរាត្រីនោះ។ ពេលទៅដល់ខាងក្នុង ឱពួកម៉ាកអើយ! វាស្អាតនិងទំនើបជាងក្លិបតន្ត្រីប៉ាស៊ីភិកឃីសដែលយើងធ្លាប់បានទៅលេងទៅទៀត។ នៅក្នុងក្លិបនោះងងិត តែដោយសារភ្លើងគ្រវីគ្រវ៉ាត់ វាបានធ្វើឱ្យគ្នាបានឃើញយ៉ាងច្បាស់ថា មានមនុស្សម្នាជាច្រើនដែលកំពុងតែផឹកស៊ី ដោយសេចក្តីសប្បាយជាទីបំផុត។ មានអ្នកខ្លះច្រៀង អ្នកខ្លះរាំហើយអ្នកផ្សេងទៀតកំពុងតែសំលឹងទៅមើលអ្នករាំនៅលើឆាក។

ពួកយើងទាំងបីនាក់បានចូលមកអង្គុយនៅឯតូនតុតូចមួយ។ គ្នាខំប្រឹងសំលឹងមើលទៅមនុស្សទាំងឡាយ គ្នាពិតជាសប្បាយចិត្តណាស់នៅពេលនោះ ហើយ គ្នាមិនបានគិតអ្វីទាំងអស់ ពីអ្វីដែលកំពុងតែកើតឡើង ឬក៏គ្នានៅទីណានោះទេ។

គ្នាបានសួរទៅនាងទាំងពីរក្រែងនាងធ្លាប់បានមកទីនេះមុនគ្នា តែនាងបានប្រាប់មកវិញថា អ្វីៗសុទ្ធ តែថ្មី ទាំងអស់សំរាប់នាង។ ពួកនាងទាំងពីរបានអង្គុយនៅអមសងខាងខ្លួនរបស់គ្នា ពេលនោះអ្នកបំរើបានចូលមកដល់ល្មម គ្នាបានសុំអ្នកបំរើឱ្យយកមកឱ្យពួកយើងនូវទឹកក្រូចពីរកែវសំរាប់បុទមវត្តីនិងស្រាបៀរហ៊ីនីហ្កែនមួយសំរាប់គ្នា។

នៅក្នុងក្លិបនោះ គ្នាបានផឹកជាច្រើនដបដែរ តែ គ្នាអត់ស្រវឹងសូម្បីតែបន្តិច។ គ្នាហាក់មានអារម្មណ៍នៅធម្មតា ធម្មតាដូចជាមិនផឹកអ្វីទាំងអស់។ គ្នាពិតជាសប្បាយនូវទិដ្ឋភាពទាំងឡាយ

នៅជុំវិញខ្លួនយ៉ាងខ្លាំង។ ខ្ញុំមើលទៅអ្នករាំនៅលើឆាក ពួកគេមានស្នាមញញឹមជាប់ជានិច្ច ពួកគេរាំផង ពួកគេសើចសប្បាយផង។ ជាការពិតដែលមានមនុស្សគ្រប់វ័យនៅទីនោះ មិនដូចជាក្លិបតន្ត្រីដែលយើងធ្លាប់ទៅនោះទេ។ ដោយទ្រាំមិនបាននិងភ្លេងដ៏រណ្តំចិត្ត ខ្ញុំបានបបួលបុទមវត្តីមករាំជាមួយគ្នា តែពីរនាក់គេនោះបានតែញញឹមនិងគ្រវីក្បាលដោយ ឆ្លើយមកវិញថាពួកនាងមិនចេះរាំទេ។ កាលនោះថ្វីបើនាងមិនមករាំជាមួយគ្នា ខ្ញុំក៏មិនខ្វល់អ្វីដែរ។ ខ្ញុំមករាំតែម្នាក់ឯងយ៉ាងសប្បាយ។ ពេលខ្ញុំបានឡើងដល់ឆាក ពួកម៉ាកអើយ ម្នាក់ៗនាំគ្នាមើលខ្ញុំគ្រប់គ្នា ហើយពិសេសនោះស្រីៗ។ ខ្ញុំអៀនដែរ តែដោយសារតែភ្លើង ភ្លឹបភ្លែតមិនសូវជាភ្លឺ ខ្ញុំចេះតែរាំទៅរាំកាច់ដៃកាច់ជើងទៅតាមចង្វាក់បទភ្លេង។ ខ្ញុំរាំផង ច្រៀងផង ហាក់បីដូចជាមិនចេះហត់ទាល់តែសោះ ហើយនៅពេលនោះដែរ ខ្ញុំបានជួបស្រីម្នាក់ បានមករាំក្បែរ។ នាងរាំមើលមកខ្ញុំ ហាក់បីដូចជានាងធ្លាប់ស្គាល់ខ្ញុំពីអង្កាល់។ ក្បាច់រាំដ៏ ល្វតល្វន់របស់នាង បានធ្វើឲខ្ញុំកាន់តែពេញចិត្តនិងរាំទល់មុខនាង។ ពួកយើងរាំ ពួកយើងច្រៀង យ៉ាងសប្បាយជាទីបំផុត។ ខ្ញុំរាំបានមួយសន្ទុះ ទើបខ្ញុំត្រលប់មកតុវិញដែលពេលមកដល់ កាន់តែបានធ្វើឲ ខ្ញុំមានកំលាំងទៅទៀតនៅពេលដែលបានឃើញស្នាមញញឹមរបស់បុទមវត្តី។

**«ម៉េចបងសប្បាយទេ?មើលទៅហត់ហើយមែនទេ?»** វត្តីសួរ

**«អត់ហត់ទេ!»** ខ្ញុំឆ្លើយទាំងធ្វើមាត់ម្លូបៗ

**«ម៉េចមិនហត់ បើបានរាំជិតកញ្ញាស្អាតទៅហើយ»** បុទមនិយាយបែបធ្វើមាត់ខឹង

ខ្ញុំសើចតិចៗដោយនិយាយបង្វែរដានវិញថា៖

**«បុទមវត្តីចង់ញ៉ាំអ្វី ញ៉ាំទៀតទៅ កុំខ្លាចចិត្តថ្លើមខ្ញុំអីណា!»**

ពួកនាងមិនឆ្លើយបានត្រឹមតែញញឹមមកដាក់ខ្ញុំ។ ពួកម៉ាកឯងដឹងទេ? នៅពេលនោះ ខ្ញុំក៏ឆ្ងល់ណាស់ដែរ ថា ខ្ញុំបានញ៉ាំស្រាបៀរជាច្រើន ចុះហេតុអ្វីបានជាខ្ញុំមិនចង់ទៅបន្ទប់ ទឹកទាល់តែសោះ? ខ្ញុំមិនដឹងថាមានរឿងអ្វីហើយខ្ញុំក៏មិនហ៊ានសួរពួកនាងទាំងពីរដែរ ព្រោះវាជារឿងកើ្តខ្មាស់។កាលនោះដែរខ្ញុំពិតជាមិនដឹងអ្វីទាំងអស់ខួរក្បាលរបស់ខ្ញុំហាក់បានភ្លេចនូវអ្វីដែលបានកន្លង នៅពេលនោះអារម្មណ៍របស់ខ្ញុំមានតែមួយគត់គឺភ្លេងតន្ត្រីដែលកំពុងតែប្រគុំ ជាពិសេសការសប្បាយរីករាយជាមួយនិងហ្វូងមនុស្សឯទៀតដែលមានវត្តមាននៅទីនោះដែរ។





កំពុងតែអង្គុយដោយស្នាមញញឹមនិងការសំលឹងទៅក្រុមអ្នករាំរបស់ពួកយើងទាំងបី វត្តីបានបន្លឺឡើងថា៖

**«ម៉េចបងចង់រាំទៀតមែនទេ?»**

**«ទៅរាំទៅបង ពួកខ្ញុំចូលចិត្តមើលបងរាំណាស់»** បុទមបន្ត

**«កុំមកបញ្ឆោរនោះ គ្មានលុយឲទេ!»** ពួកយើងទាំងបីសើចព្រមគ្នា។ ឯខ្ញុំបានបន្តទៅទៀតថា៖

**«ខ្ញុំមិនចេះរាំម្នាក់ឯងទេ សុខចិត្តមើលគេវិញសប្បាយជាង!»**

**«ឥចឹងមករាំជាមួយខ្ញុំ»** វត្តីបន្លឺ

ខ្ញុំបើកភ្នែកធំៗព្រោះមិននឹកស្មានថានាងចង់រាំទាល់តែសោះ។ ពីរនាក់យើងបានឡើងមកលើឆាកទាំងពីរនាក់។ ជួនជាពេលនោះត្រូវចំបទស្លូវ ពួកម៉ាកអើយ! ខ្ញុំចាប់ចង់កេះនាងទាំងពីរមុនពេលដែលនាងលើកដៃដាក់លើស្មារបស់ខ្ញុំ។

ពួកយើងបានយោលខ្លួនពីឆ្វេងទៅស្តាំទៅតាមបទភ្លេងដ៏ពិរោះគួរស្រឡាញ់។

ជាការពិតដែលបុទមនិងវត្តីជាបងប្អូននិងគ្នា ពួកនាងពិតជាស្អាតណាស់ ស្អាតដូចជា ទេពអប្សរ។ នៅពេលកំពុងរាំ ហើយពេលដែលខ្ញុំបានប៉ះចង្កេះរបស់នាង ស្បែដ៏ទន់ល្មើយរួមជាមួយនិងចង្កេះដ៏មូលខ្ញំរបស់នាង បានធ្វើឲខ្ញុំបាស់ដៃបាស់ជើង ស្ទើរតែបាត់ស្មារតី។ តែទោះយ៉ាងណាក៏ដោយខ្ញុំបានទប់អារម្មណ៍ដោយមិនគិតចង់ធ្វើអ្វីផ្តេសផ្តាសនោះទេ។ កំពុងតែរាំអោបគ្នាដ៏ស្អិតរម្មួតនោះ ខ្ញុំក៏បានគិតទៅដល់ដានិត គូដណ្តឹងជាទីស្រលាញ់របស់ខ្ញុំដែលខ្ញុំបានស្រមៃថាបើសិនជានាងនៅទីនេះជាមួយគ្នា មិនដឹងថាពួកយើងមានសេចក្តីសុខប៉ុណ្ណានោះទេ។ តែផ្ទុយទៅវិញ បើនាងបានឃើញខ្ញុំស្ថិតនៅក្នុងសភាពបែបនេះវិញ ខ្ញុំប្រាកដជាអារយះក្បាលមិនខានទេ។ ហើយរឿងរ៉ាវផ្តាច់ពាក្យប្រាកដជាកើតមានឡើង។ ទោះយ៉ាងណាខ្ញុំនៅតែបន្តការរាំអោបទៅទៀតដោយក្នុងចិត្តគិតថា មិនអាចនាងមើលខ្ញុំឃើញនោះទេព្រោះតែក្នុងបារងងឹត ម្យ៉ាងទៀតនាងកំពុងតែធ្វើការឬក៏គេងផងមិនដឹង។ ហើយបើមាន ការភ្ញាំងភ្ញាត់នោះ យ៉ាងហោចណាស់ខ្ញុំមានខ្សែរកនិងចិញ្ចៀនទុកលួងនាងដែរ។ អ្វីដែល ខ្ញុំនិយាយ នេះវាមិនខុសអ្វីពីគំនិតពួកម៉ាកឯងទេ។ ខ្ញុំដឹងតើ ថាពួកយើងពេលខ្លះខូចដែរ ជាមួយស្រី។

ពូកែខាងញោះគេឲខឹងហើយទើបលួងគេជាក្រោយ។

គ្នារាំបណ្ដើរសើចបណ្ដើរតែម្នាក់ឯង ដោយគិតនៅក្នុងចិត្តទៀតថា ប្រសិនបើមានចាន់ណារិនឯងនៅទីនេះដែរ ហើយនៅពេលដែលបានឃើញគ្នាកំពុងតែរាំជាមួយកញ្ញាដ៏ស្រស់ប្រិមប្រិយនេះ មិនដឹងថាចាន់ណារិនឯងប្រណែនប៉ុណ្ណា ហើយមិនដឹងទៅទូពិតដានិតយ៉ាងម៉េចនោះទេ? គ្នាគិតនៅក្នុងចិត្តតែម្នាក់ឯងហើយសើចឲកក្អឹក នៅពេលដែលគ្នាកំពុងតែអោបវត្តីនៅនិងទ្រូង។ឃើញគ្នាសើចដោយគ្មានមូលហេតុដូច្នេះនាងបានសួរមកគ្នាថា៖

«ម៉េចក៏បងសើច?»

គ្នាអោនមុខមើលទៅនាងហើយតបដោយថ្នមៗវិញថា៖

«បងកំពុងតែគិតទៅមិត្តភក្តិបងម្នាក់»

«អ្នកណាគេបង?»

«ចាន់ណារិន»

«អ្នកណាគេចាន់ណារិន?»

«ចាន់ណារិនជាពួកម៉ាកបង ពួកម៉ាកចិត្តមួយថ្លើមមួយ ពួកយើងបានស្គាល់គ្នាជាច្រើនឆ្នាំណាស់មកហើយ ថ្វីបើគេមានអាយុតិចជាងបងតែពួកយើងត្រូវគ្នាណាស់។ យើងទៅណាទៅទាំងពីរនាក់មិនដែលខាន។ តែឥឡូវនេះគេទៅសិក្សានៅឯប្រទេសបារាំងឯណោះ អ្វូយបើនិយាយពីអនុស្សាវរីយ៍រវាងយើងទាំងពីរនោះវាច្រើនណាស់ មិនអីទេចាំមានពេលទំនេរចាំបងប្រាប់អូនម្ដងទៀត» គ្នានិយាយរាងបែបខ្ជិល

នាងញញឹមទទួលការបញ្ជប់សេចក្ដីរបស់គ្នា ហើយនាងក៏បែរទៅយកក្បាលរបស់នាងមកដាក់លើទ្រូងរបស់គ្នាបន្តទៅទៀត។

ពួកម៉ាកអ្អើយ ពេលនោះគ្នាពិតជាត្រជាក់ខ្លួនស្រេប នៅពេលដែលថ្ពាល់ដ៏ទន់រលោងរបស់នាងប៉ះនិងដើមទ្រូងរបស់គ្នាសារជាថ្មី។ ពេលនោះគ្នាសប្បាយបន្តិច ហើយក៏ដូចជាចង់តាំងបេះដូងម្ដងៗនោះដែរ។គ្នាបើកភ្នែកធំៗហើយធ្វើមុខដូចជាស្វា នៅពីលើសក់ក្បាលរបស់នាងក្រោមចង្ការរបស់គ្នា។ រាំអោបស្រីស្រស់ប្រិមប្រិយ វាជាសេចក្ដីសុខមួយដែលបានធ្វើឲ គ្នាបានរសាយអស់នូវការហត់នឿយទាំងឡាយ តែទោះបីយ៉ាងនោះក៏ដោយគ្នាមិនដែលបានភ្លេចគូរដណ្ដឹង



ស្រមៃ ឃេឌី

របស់គ្នាក្នុងមួយវិនាទីណាឡើយ។

គ្នាសប្បាយ គ្នាអរមែននៅពេលដែលនាងរាំអោបគ្នាបែបនេះ តែគ្នាក៏ពិតជាអៀនណាស់ដែរនៅពេលដែលអ្នករាំឯទៀតបានសំលឹងមកមើលគ្នាមិនដេះដាច់។ ដូច្នេះហើយបានជាបន្តិចក្រោយមកគ្នាបានខ្សឹបដាក់ត្រចៀកនាងថា៖

«តោះអូនយើងឈប់ទៅហើយ»

«ម៉េចបងប្រញាប់ទៅម្លេះ?» នាងងើបក្បាលពីដើមទ្រូងរបស់គ្នាហើយសួរ

«ដឹងទេ ខ្ញុំពិតជាអាណិតបងខ្លាំងណាស់ ហើយតែងតែចង់បំរើនូវអ្វីដែលបងត្រូវការ ដើម្បីឲបងសប្បាយ ឲបងបានភ្លេចពីរឿងអតីតកាល» នាងបន្ត

សំដីដ៏ផ្អែមល្ហែមរបស់នាងបានបង្ខំដៃរបស់គ្នាឲទៅអង្អែលសក់របស់នាងថ្នមៗនិងបន្ទឹតបរិញថា៖

«កុំគិតដូចនេះអី ខ្ញុំមិនអីទេ ខ្ញុំសប្បាយហើយតើ ម្យ៉ាងទៀតខ្ញុំក៏មានគូរដណ្ដឹងហើយដែរ»

នាងមើលមុខគ្នាដោយកែវភ្នែករលីងរលោងហើយគ្នាបានបន្តទៀតថា៖

«នាងមានឈ្មោះដានិត នាងមានអាយុប្រហែលជាវត្តីឯងដែរ ខ្ញុំបានស្គាល់នាងជាច្រើនឆ្នាំណាស់មកហើយ។ ពួកយើងបានធ្វើការជាមួយគ្នា តែក្រោយមកដោយសារមានគេច្រណែនឈ្នានីសនិងរករឿងខ្ញុំគ្រប់ពេលនោះ នៅទីបំផុតខ្ញុំបានត្រូវគេបញ្ឈប់ពីការងារដោយ អយុត្តិធម៌ជាទីបំផុត។ សំរាប់ពីរនាក់យើងវិញ ទោះបើមានបញ្ហាការងារនិងចំណូលដូចនេះក៏ដោយពួកយើងទាំងពីរនឹងរៀបការជាមួយគ្នានៅឆ្នាំក្រោយខាងមុខនេះ»

គ្នានិយាយបណ្ដើរយកដៃទៅអង្អែលក្បាលនាងបណ្ដើរដោយសេចក្ដីស្រលាញ់រាប់អានដ៏ស្មោះស្ម័គ្រ។គ្នាបានបន្តដោយសើចញឹមៗថា៖

«កុំភ័យអី នៅពេលដែលខ្ញុំរៀបការខ្ញុំនឹងហៅពីរនាក់បងប្អូនយើងទៅចូលរួមមិនខាន»

នាងមិនបាននិយាយអ្វីមួយម៉ាត់តែនាងទៅជាមានទឹកមុខស្រពោបស្រពោនទៅវិញ។ គ្នាហាក់ទទួលអារម្មណ៍នៅក្នុងចិត្តថានាងកំពុងតែអាណិតគ្នា នោះបើតាមអ្វីដែលគ្នាបានឃើញនៅក្នុងកែវភ្នែករបស់នាង។ គ្នាបានគិតថានៅពេលដែលគ្នានិយាយរឿងនេះប្រាប់នាង ជាការពិត

ណាស់ដែលគ្នាបាននឹងកំពុងតែបំបែកបេះដូងរបស់នាង ហើយគ្នាបានដឹងថានាងប្រហែលជាកំពុងតែតូចចិត្ត តែធ្វើម៉េចបើជាតិនេះ គ្នាបានជួបជានិតមុននាងទៅហើយ។ ពីរនាក់យើងបានបញ្ចប់ការសន្ទនាត្រឹមនេះរួចទើបបានយើងត្រលប់មកតុដែលមានបុទមកំពុងចាំវិញ។

**«បុទមមិនខឹងខ្ញុំទេដែលយកវត្តីទៅរាំឥចឹង»**

នាងញញឹមដោយតបមកវិញថា៖

**«ពួកខ្ញុំមានជីវិតដោយសារបង ហើយពួកខ្ញុំមកនេះគឺមកថែរក្សានិងបង្ហាត់បង្ហាញផ្លូវបងពិសេសនោះចង់ឲបងបានសប្បាយចិត្ត និងភ្លេចនូវរាល់ទុក្ខកង្វល់ទាំងឡាយដែលបងធ្លាប់តែមានកន្លង ពួកខ្ញុំចង់ឲបងបានរស់នៅក្នុងភពសន្តិភាពនិងភាពសប្បាយរីករាយជានិច្ច តើធ្វើម៉េចនិងខឹងបងបានបើបងជាលោកម្ចាស់របស់ពួកយើងទៅហើយ។»**

គ្នាញញឹមទទួលពាក្យរបស់នាងដោយពេញចិត្តហើយបែរមកនិយាយត្រលប់មកវិញថា៖

**«តោះពួកយើងល្មមទៅហើយ»** គ្នាងាកមុខចេញដោយបន្តនិយាយ៖

**«ឯណាទៅ អ្នកគិតលុយនោះ?»**

**«កន្លែងនេះគេអត់គិតលុយទេ»** បុទមឆ្លើយដែលនាងនៅខាងឆ្វេងដៃរបស់គ្នាដែលពេលនោះគ្នាស្ទើរតែមើលនាងមិនទាំងឃើញផងព្រោះតែវាងងឹតនិងភ្លើងវិលខ្លាំងពេក។

ដោយមានការអះអាងយ៉ាងនេះ ពួកគ្នាទាំងបីបានចេញពីក្លិបរាត្រីមកកាន់មណ្ឌលកណ្ដាលវិញដោយមិនបានបង់ប្រាក់អ្វីទាំងអស់។មកដល់មណ្ឌលកណ្ដាល ភ្នែករបស់ គ្នារាងស្រវាំងបន្តិចតែគ្នានៅតែឃើញមានមនុស្សម្នាជាច្រើននាក់កំពុងតែធ្វើដំណើរមិនចេះអស់មិនចេះហើយ។ ឯ គ្នាមិនហ៊ានសួរពួកនាងថាពួកគេទាំងនេះទៅណាមកណានោះទេព្រោះវាជាការពិតដែលគ្នាអៀនហើយម្យ៉ាងទៀតមិនសមអីទៅសួរសំនួរបែបនេះផង។

ពួកយើងបានបណ្ដើរគ្នាមកមុខទៀត រហូតបានមកដល់ក្លិបកំសាន្តមួយដ៏ធំនៅឯខាងឆ្វេងដៃមណ្ឌលកណ្ដាល។ពួកគ្នាទាំងបីបានចូលទៅខាងក្នុង វាពិតជាសប្បាយណាស់ចាន់ណារិន អើយ វាជាលើកទីមួយហើយដែលគ្នាបានសប្បាយបែបនេះ។ ពួកគ្នាទាំងបីបានមកឈរតំរង់ជួរគ្នាដើម្បីមើលកុនម្យ៉ាង។ ការចូលមើល វាជាក្រុម ហើយក្នុងមួយក្រុមមានគ្នា ប្រមាណជា១០០នាក់។ នៅក្នុងបន្ទប់ខ្សែរភាពយន្តនោះ គេបានបញ្ចាំងរូបសត្វពស់មួយដ៏ធំហាក់បីដូចជា





ការពិត។រូបពស់នោះវាហាក់បីដូចជាចង់ហក់មកត្របាក់កពួកអ្នកមើលទាំងអស់គ្នា។រូបភាពដ៏ស្ដែងនិងជិតភ្នែកដូចនេះ វាបានធ្វើឲម្នាក់ៗនៅក្នុងរោងកុន មានការភិតភ័យយ៉ាងខ្លាំងព្រោះតែរូបពស់ដូចជាពស់មែនទែនហើយម្យ៉ាងហាក់ដូចជានៅចំពីមុខរបស់យើង។ សំលេងរបស់វាបានធ្វើឲបេះដូងអ្នកទស្សនាគ្រប់គ្នាបានញ័រចំប្រប់។ សូម្បីតែ គ្នាក៏មានអារម្មណ៍ខ្លាចដែរនៅពេលនោះ តែគ្នាបែរជាអស់សំណើចទៅវិញនៅពេលដែលបានឃើញ បុទមនិងវត្តីនាំគ្នារួញខ្លួន ហើយខំស្រវាអោបគ្នាទាំងពីរដោយបិទភ្នែកផង។ ពីរនាក់គេខ្លាចណាស់ ហើយបានគៀនគ្នាឲចេញមកក្រៅវិញ ឲទៅលេងល្បែងដែលមិនសូវជាខ្លាចដូចនេះ។ គ្នាបាននិយាយទៅកាន់ពួកនាងទាំងសើចថា៖

**«កុំខ្លាចអី វាគ្រាន់តែជាខ្សែរភាពយន្តទេតើ! កុំខ្លាច! ពស់នោះមិនស៊ីយើងមែនទែនទេ!»**

ទោះបីគ្នាខំពន្យល់យ៉ាងណាក៏ដោយពួកនាងគ្រវីក្បាលឥតគាត់ហើយដេញ គ្នាឲចេញពី ទីនោះ។ គ្នាសើចតែម្នាក់ឯងនៅពេលដែលឃើញនាងខ្លាចដូចជាកូនក្មេងដូចនេះ។ គ្នាសប្បាយណាស់នៅពេលដែលគ្នាបាននៅទីនោះជាមួយពួកនាង។

បន្ទាប់ពីចេញពីរោងកុនមក គ្នាបានឃើញកន្លែងមួយទៀតនៅពីមុខបន្ទប់កុន។ នៅបន្ទប់កំសាន្តនោះគេដាក់ផ្លាកថា៖

**«សូមស្វាគមន៍នៃការមកដល់ផ្ទះខ្មោច!»**

គ្នាបានយកដៃទៅចង្អុលបង្ហាញទៅពួកនាងដែលមិនទាន់ទាំងបាត់ញ័រផងហើយសួរក្រែងលោចង់ចូលមើល។បុទមវត្តីកាលបើបានយល់ពីអត្ថន័យនៃផ្លាកនោះហើយពួកគេបានបើកភ្នែកធំៗដោយចង់បញ្ជាក់ថាពួកនាងមិនចង់ចូលឡើយ។ ឃើញដូចនេះ គ្នាក៏មិនចង់ធ្វើបាបនាងដែរហើយពួកយើងបានបន្តដើរមកខាងមុខទៀត រហូតមកដល់កន្លែងលេងមួយដែលនៅទីនោះគ្នាបានឃើញកាណុងមួយដ៏ធំដូចជាកាំជ្រួច។ គ្នាបានសួរទៅពួកនាងម្ដងទៀត។ ពួកគេបានយល់ព្រម ហើយពួកយើងបានឡើងជិះព្រមគ្នា។ នៅលើកាំជ្រួចដែលមានផ្ទៃធំនៅខាងក្នុងពួកយើងមិនទាន់ទាំងបានដាក់គូទស្រួលបួលផងស្រាប់តែកាំជ្រួចនោះបានហោះហ្មឹង។

គ្នាមិនអាចដឹងថាល្បឿនប៉ុន្មានទេ តែគ្នាអាចដឹងថាល្បឿនរបស់វាបានធ្វើអាយគ្នាបះសក់សំពោង។ ពេលដែលកាំជ្រួចកំពុងតែហោះ គ្នាមិនបានលឺអ្វីទាំងអស់ក្រៅអំពីសំលេងស្រែក

របស់អ្នកជិះជាមួយពួកយើង ហើយជាការពិតណាស់ដែលគ្នាបានដឹងថាបុទមវត្តីបានស្រែកខ្លាំងជាងគេព្រោះតែនាងនៅជិតនិងត្រចៀករបស់គ្នា។ គ្នាមិនដឹងថាពេលនោះគ្នាបានស្រែកឬទេ តែគ្នាមានអារម្មណ៍ថាមាត់របស់គ្នាបានហារដូចជាគេដែរ។ កាំជ្រួចនោះបានហោះនាំពួកយើងទៅក្រៅពិភពផែនដី ដែលនៅទីនោះគ្នាបានឃើញផ្កាយ ព្រះអាទិត្យ ព្រះច័ន្ទនៅជាប់និងកែវភ្នែក។ នៅទីនោះដែរប្រាកដណាស់ដែលមានខ្យល់បរិសុទ្ធបក់បោកយ៉ាងខ្លាំងហើយជាពេលដែលគ្នាបានសំលឹងមើលទៅបុទមវត្តីដែលកំពុងតែហារមាត់គ្រប់គ្នាព្រោះតែសេចក្តីភ័យខ្លាច។ កាំជ្រួចបាននាំពួកយើងហោះលេងហាក់បីដូចនៅក្រៅភពមួយសន្ទុះ ទើបកាំជ្រួចនោះនាំពួកយើងត្រលប់មកកន្លែងដើមវិញ។ ពេលមកដល់ក្រោម គ្នាមានអារម្មណ៍អាណិតបុទមវត្តី ណាស់ព្រោះចង់ក្អួតផងចង់ដួលផង។ គ្នាខំទប់កាន់ដៃនាងឲប្រមូលអារម្មណ៍បានល្អវិញ។ សំរាប់គ្នាការជិះត្រលប់ត្រលិននោះគ្មានអ្វីជាបញ្ហាទេ គ្នាហាក់នៅមានសុខភាពល្អ។គ្នាបានគិតនៅក្នុងចិត្តថាប្រហែលជាបេះដូងរបស់គ្នានៅដំណើរការបានល្អនៅឡើយ។

ក្រោយពីឈប់សំរាកនៅទីនេះបន្តិច ពួកយើងបានដើរចេញមកក្រៅទៀត។ មកដល់កន្លែងមួយដែលមានមនុស្សម្នាជាច្រើនរាប់រយនាក់កំពុងតែឈរតំរង់ជួរគ្នាចុះឈ្មោះ។ នៅពេលនោះគ្នាមិនបានដឹងថាពួកគេចុះឈ្មោះធ្វើអ្វីឬត្រូវទៅណានោះទេ។ ពួកយើងទាំងបីបានមកឈរនៅក្រោយគេដែរ។ គ្នាបានសួរទៅបុទមថា៖

**«តើគេកំពុងធ្វើអីដែរ?បុទមមានដឹងដែរឬទេ?»**

**«ខ្ញុំមិនដឹងដែរបង»** បុទម

**«ចាំមើលទៅ តើគេធ្វើអ្វីយើងធ្វើតាមគេទៅ»** ម្នាក់ៗនៅស្ងៀមក្រោយពីវត្តីបាននិយាយពាក្យនេះឡើង។

ពួកយើងបានបន្តនៅឈររងចាំពីម្នាក់ទៅម្នាក់។ ដល់វេនក្រុមដែលនៅមុខយើង អ្នកទទួលភ្ញៀវបានសួរទៅគាត់ថាចង់ទៅណា? ក្រុមខាងមុខយើងដែលមានបុរសចំណាស់ជាមេប្រធាន បាននិយាយថាគាត់ចង់បានយន្តហោះមួយទុកគ្រាន់ជិះជុំវិញពិភពលោក។

គ្នាបើកភ្នែកធំៗដោយនឹកនៅក្នុងចិត្តថាបុរសនេះមានម៉្លេះ ចង់ជិះយន្តហោះមួយតែម្នាក់ឯង។





គ្នាដែលនៅពីក្រោយគាត់ តែគ្នានៅតែមិនទាន់ដឹងគោលដៅច្បាស់លាស់ថា ចង់ទៅណាហើយចង់បានអ្វីជាយានជំនិះ?

ក្រុមរបស់បុរសនោះបានចេញផុតទៅ វាត្រូវមកដល់វេនរបស់គ្នាតែម្តង ដែលត្រូវនិយាយជាមួយអ្នកទទួលភ្ញៀវ។

**«ជំរាបសួរបង»** គ្នាពោលថ្មមៗ

**«ជំរាបសួរ បងទើបមកដល់ថ្មីមែនទេ?»** អ្នកទទួលភ្ញៀវសួរ

គ្នាងាកទៅមើលបុទមវត្តីបន្តិចហើយងាកមកឆ្លើយនិងអ្នកទទួលភ្ញៀវនោះវិញថា៖

**«បាទបងខ្ញុំទើបតែមកដល់»**

**«បងឈ្មោះអ្វី?»**

**«ខ្ញុំឈ្មោះគៀនកា»**

គាត់ងក់ក្បាលបណ្តើរ ទន្ទិញឈ្មោះគ្នាបណ្តើរនិងមើលទៅក្នុងបញ្ជីឈ្មោះដែលនៅលើតុរបស់គាត់បណ្តើរ។ ពេលដែលគាត់រកឈ្មោះគ្នាឃើញហើយ គាត់បានងើបមុខមកមើលគ្នាវិញហើយពោលទាំងញញឹមថា៖

**«តើបងចង់បានអ្វីហើយចង់ទៅណា?»**

ពេលនោះគ្នានៅស្ងៀមដោយដកដង្ហើមធំមួយព្រោះគ្នាមិនដឹងថាចង់បានអ្វីនោះទេ។ គ្នាងាកមកមើលបុទមនិងវត្តីសារជាថ្មីតែពួកនាងមិនបាននិយាយអ្វីទាំងអស់ក្រៅពីញ៉ូចស្មាបន្តិចដោយមានន័យថាទុកឲគ្នាជាអ្នកសំរេចចិត្ត។ គ្នាយកដៃមកអង្អែលកបន្តិច គិតបែបរុញរាថាមិនដឹងត្រូវទៅណាហើយយកអ្វី។គ្នាដកដង្ហើមធំមួយទៀត បន្ទាប់មកឆ្លើយឡើងថា៖

**«ខ្ញុំចង់បានកប៉ាល់មួយសំរាប់ដំណើរកំសាន្តលើទ្វីបទាំងប្រាំនៅក្នុងលោកបានទេបង?»**

ពេលនិយាយចប់គ្នាបានងាកមករកនាងទាំងពីរវិញគេបើកភ្នែកធំៗដោយពេញចិត្តនៃក្តីបំណងរបស់គ្នាដែរ។

អ្នកទទួលភ្ញៀវងក់ក្បាលហើយបានហុចសោមកឲគ្នាព្រមជាមួយនិងឃ្លាដ៏សុភាពរៀបសារថា៖

**«សូមបងទៅលេងឲបានសប្បាយ»**

គ្នាបានទទួលសោពីគាត់ព្រមជាមួយនិងពាក្យអគុណ រួចហើយទើបពួកយើងទាំងបីបានដើរ

ចេញពីទីនោះ។ពួកគ្នាដើរបណ្ដើរសំលឹងទៅមើលមនុស្សម្នាដែលនៅជិតគ្នាបណ្ដើរដែលម្នាក់ៗ ហាក់បីដូចជាគ្មានទុក្ខព្រួយអ្វីសោះឡើយ។ មើលមកបុទមវត្តីវិញ ស្នាមញញឹមមាននៅជាប់ បបូមាត់ជានិច្ច។ ពួកគ្នាបានដើរនៅលើផ្លូវធំរហូតមកដល់កាច់ជ្រុងមួយដែលវត្តីបានប្រាប់ថា ជាផ្លូវដែលពួកយើងត្រូវទៅកាន់កប៉ាល់ហើយ។គ្នាមិនដឹងហើយក៏មិនស្គាល់ដូចនេះហើយគ្មាន អ្វីដែលត្រូវប្រកែកពីការប្រាប់របស់វត្តីឡើយ។យើងបានបត់ចូលទៅកូនផ្លូវដ៏តូចនោះហើយបន្ត ការដើររហូតដល់យើងចេញផុតពីមណ្ឌលចំលែក ហើយជាពេលដែល គ្នាបានជួបនូវ ទិដ្ឋភាព ថ្មី។

ពុទ្ធោអើយ! គ្រាន់តែគ្នាបានមកដល់ក្រៅភ្នាម គ្នាបានឃើញកប៉ាល់មួយដ៏ធំសំបើម គ្នាក្រលេក ងើយមើលរហូតដល់ផុតកញ្ចឹងកទើបអាចឃើញទង់ជ័យរបស់កប៉ាល់នៅខាងចុងបាន។

គ្នាមិនបាននឹកស្មានទាល់តែសោះថាកប៉ាល់នេះជារបស់គ្នា គ្នាបើកភ្នែកធំហើយសួរទៅអ្នក ទាំងពីរថា៖

«**តើកប៉ាល់នេះសំរាប់ពួកយើងមែនទេ?**»

«**ជាធម្មតាវាត្រូវតែជារបស់ពួកយើង**» បុទមឆ្លើយ

«**ចាំអីទៀតបង ម៉េចមិនយកសោទៅចាក់សាកលមើល?**» វត្តីបន្ទរ

«**និយាយត្រូវមែនចាំបងចាក់សាកលមើលសិន**»

ចប់សំដីពួកយើងបានដើរទៅជិតកប៉ាល់នោះ ដែលនៅពីមុខទ្វារយើងបានឃើញរន្ធតូចមួយ សំរាប់ដាក់សោរ។ គ្នាបានយកសោរទៅដាក់ទៅតាមអ្វីដែលវត្តីបានប្រាប់។ មែនចាន់ណារិន អើយ! គ្រាន់តែគ្នាដាក់សោចូលភ្នាមនោះ ស្រាប់តែកប៉ាល់បានបើកទ្វារបន្តិចម្ដងៗ។ គ្នាពិត ជាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ពួកយើងទាំងបីបាននាំគ្នាឡើងទៅខាងលើកប៉ាល់។ ដូចជា ពួកម៉ាកឯងដឹងស្រាប់ហើយថាគ្នាមិនដែលទៅរៀនបើកកប៉ាល់ ឬមួយក៏ចេះបើកកប៉ាល់អ្វីដែរ តែនៅពេលនោះគ្នាមិនដឹងថាហេតុអ្វីទេ នៅពេលដែលគ្នាបានប៉ះដៃចង្កូតភ្លាមហាក់បីដូចជា មានអ្វីប្រាប់មកគ្នាថាត្រូវធ្វើបែបណា។គ្នាបានក្លាយទៅជាមនុស្សម្នាក់ដែលស្គាល់ពីការ បញ្ជា ម៉ាស៊ីននិងការកាន់ចង្កូតយ៉ាងណែននៅពេញដៃ។ ជាការពិតណាស់ដែលនៅលើកប៉ាល់នោះ គ្មានអ្នកណាទាំងអស់ក្រៅពីពួកយើងទាំងបី។ នៅពេលនោះហើយដែលគ្នាបាននឹកដល់





អនុស្សាវរីយ៍របស់បួននាក់យើង (គ្នា,ចាន់ណារិន,ដានិតនិងជាតា) ដែលពួកយើងទាំងបួននាក់ បានមកលេងនៅឯក្រុងព្រះសីហនុជាញឹកញាប់។

នៅទីនោះហើយដែលពួកយើងបាននាំគ្នាសប្បាយ ជាមួយការដុតសាច់និងម្ហូមអាហារទាំង ឡាយដែលយើងបានធ្វើរួមគ្នា។ គ្នានៅចាំថាពួកយើងបាននាំគ្នាជជែករហូតដល់យប់ៗជ្រៅ។ គ្នាមិនដឹងទេពេលនោះ ថាហេតុអ្វីបានជា គ្នាមិននឹកចង់ទូរស័ព្ទហៅទៅដានិតនិងជាតាឲបាន មកលេងនៅលើកប៉ាល់របស់គ្នាដែរ ប្រហែលជាពេលនោះគ្នាមានអារម្មណ៍ថាពួកគេនៅឆ្ងាយ ពីគ្នាឬមួយក៏ពួកគេមានការជាប់រវល់។

បុទមវត្តីបានមកអង្គុយព្រមៗគ្នានៅក្បែរគ្នាដែលជាអ្នកកំពុងតែបញ្ជាដៃចង្កូត។ គ្នាពិតជា សប្បាយនិងការបើកបរនៅលើទឹកណាស់ វាបានធ្វើឲគ្នារំភើបជាទីបំផុត រំភើបនៅ ពេលដែល បាតកប៉ាល់បានប៉ះទៅនិងទឹកសមុទ្រលឺសូរគ្រាំងៗ។

គ្នាបានភ្លេចរឿងពីអតីតហើយបែរជាមកនិយាយពីរឿងបច្ចុប្បន្នទៅវិញ ទៅកាន់អ្នកទាំងពីរ៖

«**មើលប្រាប់មកថាបុទមវត្តីចង់ទៅណាមុនគេ?**»

វត្តីបានចង្អុលដៃទៅកោះមួយដែលឆ្ងាយស្ទើរតែមើលមិនឃើញទៅហើយ។ គេប្រាប់គ្នាដោយ សំលេងគួឲស្រលាញ់ថា៖

«**អូនចង់ទៅកោះនោះបង**»

ដោយចង់បំពេញបំណងបងប្អូនរបស់គេទាំងពីរឲបានសប្បាយនោះ គ្នាបានបញ្ជាចង្កូតឆ្ពោះ សំដៅទៅកាន់ទីកោះដែលវត្តីចង់ទៅទស្សនា។ កប៉ាល់បានចេញដំណើរដំបូងសន្សឹមៗរហូត ដល់ល្បឿនមួយដ៏អស្ចារ្យ ដែលធ្វើឲទឹករលកកាន់តែបោកបក់កប៉ាល់កាន់តែខ្លាំង។ គ្នាពិតជា សប្បាយនិងមានសេចក្ដីសុខជាទីបំផុត។ វាជាគ្រាដំបូងដែលគ្នាចេះបើកកប៉ាល់ដោយខ្លួនឯង មិនចាំបាច់មានគ្រូបង្រៀន។គ្នាធ្លាប់តែបានគិតថាការបើកនៅលើទឹកវាមានការលំបាកជាងការ បើកបរនៅលើថ្នល់តែតាមពិតទៅវាស្រួលជាងបើកឡានទីក្រូរបស់គ្នាទៅទៀត។

ពេលដែលកប៉ាល់បានរត់ល្បឿនស្មើ ហើយនៅពេលដែលរលកបានស្ងប់ឈប់បោក គ្នាបាន បញ្ជាវាឲរត់តាមប្រព័ន្ធស្វ័យប្រវត្តិ ហើយគ្នានិងបុទមវត្តីបានចុះមករត់លេងនៅខាងមុខរាន

កប៉ាល់។ ពេលនោះហើយដែលគ្នាបានដឹងថា ពិភពលោកយើងនេះធំប៉ុណ្ណា។ ផ្ទៃសមុទ្រដ៏ធំល្វឹងល្វើយវាពិតជាគួរឲស្រលាញ់និងចង់គយគន់ជាទីបំផុត។ គ្នាបានក្រលេកទៅម្ខាង គ្មានឃើញកោះត្រើយអ្វីឡើយ ហើយបើមើលមកឆ្វេងវិញក៏មានភាពមិនខុសពីគ្នាដែរ។ វាជាទីកន្លែងដែលមនុស្សផងទាំងពួងចង់មកស្រូបយកខ្យល់អាកាសដ៏បរិសុទ្ធ។ គ្នាបានអោនក្បាលមើលទៅខាងក្រោមកប៉ាល់ដែលវាកំពុងតែរុលទៅខាងមុខ វាបានបុកនិងទឹកសមុទ្រឥតមានឈប់ឈរ។ នៅពេលនោះហើយដែលម្នាក់ៗបានស្រែកសប្បាយនៅពេលដែលបានឃើញ ក្កូនត្រីបាឡែនកំពុងតែហែលប្រជេញនិងចុងក្បាលកប៉ាល់នោះ។ ពួកគេលោតចុះលោតឡើង ហាក់បីដូចជាចូលរួមនិងការសប្បាយរបស់ពួកយើងដែរ។ គ្នាបានគ្រវីក្បាលនៅពេលដែលគ្នាកំពុងអោនទៅខាងក្រោម សប្បាយចិត្តព្រោះមិនដែលនឹកស្មានថាមានថ្ងៃនេះសោះឡើយ។ពួកគ្នាទាំងបីបានបន្តការមើលមហាសមុទ្រដ៏ធំល្វឹងល្វើយនោះមួយសន្ទុះធំ។ បុទមបានសួរមកគ្នានៅពេលដែលគ្នាកំពុងតែបណ្តែតអារម្មណ៍នៅលើផ្ទៃសមុទ្រនោះថា៖

**«បងមើលទៅហាក់បីដូចជាចូលចិត្តទឹកសមុទ្រណាស់មែនទេ?»**

គ្នាញឹមៗហើយតបទៅវិញថា៖

**«ពិតហើយបុទម គ្រប់ពេលដែលខ្ញុំបានងូតទឹកសមុទ្រ ខ្ញុំតែងសុំសេចក្តីសុខពីគេ ខ្ញុំយល់ថាទឹកសមុទ្រហាក់បីដូចជាមានវេទមន្តម្យ៉ាងជាងដែនដី វាពិតជាអ្វីម្យ៉ាងដែលអស្ចារ្យ»**

គ្នានិយាយបណ្តើរគ្រវីក្បាលតិចៗបណ្តើរដោយស្ញើចនិងធម្មជាតិដែលបានបង្កើត មហាសមុទ្រ។ នាងទាំងពីរបានញញឹម ហើយពេលនោះបុទមបានស្រែកឡើងថា៖

**«បងមើលណ៎!យើងជិតមកដល់កោះនោះហើយ»**

គ្នាបានក្រលេកទៅតាមដៃរបស់នាង ហើយបានឃើញពិតជាជិតដល់មែន។ គ្នាបានប្រញាប់យកដៃចង្កូតវិញដើម្បីបន្ថយល្បឿន និងរកកន្លែងដែលអាចចុះចតបាននៅជិតកោះនោះ។ កប៉ាល់ពិតជាធំណាស់ពួកម៉ាកអើយ! តែគ្នាចតវាស្រួលជាងរកកន្លែងចតរថយន្តទៅទៀត។ គ្នាបានដាក់វាឲចតនៅកន្លែងមួយជាប់និងច្រាំង។ ពេលដែលពួកគ្នាបានចុះពីលើកប៉ាល់មកជាន់ជើងនិងកោះនោះ គ្នាមិនដឹងថាត្រូវនិយាយបែបណានោះទេ វាគឺជាកោះដ៏តូចមួយនៅចំកណ្តាលមហាសមុទ្រ។ កោះនោះមិនមានទំហំធំទេ ជាកោះដែលមានអាស្រមតូចមួយ





ហើយនិងមានរូបសំណាក់ព្រះពុទ្ធមួយអង្គ។ បើកោះមិនធំតើអាស្រមអាចធំយ៉ាងណា អាស្រមរិតតែតូចទៅទៀត តូចរហូតដល់តែពួកយើងអាចចូលបានត្រឹមតែគ្នាពីរឬបីនាក់ប៉ុណ្ណោះ ដើម្បីគោរពព្រះពុទ្ធិដិមាករ។ មានមនុស្សម្នាជាច្រើនបាននាំគ្នាបន្តកន្ទុយគ្នា ដើម្បីចូលទៅដុតធូបសុំសេចក្តីសុខ។ ពួកគ្នាក៏មិនខុសពីពួកគេប៉ុន្មានដែរ កាលបើមានរូបព្រះដូចនេះ តែងបានចូលគោរពបន់ស្រន់ជាដរាប។

ពេលមកដល់ក្នុងអាស្រម ពួកយើងទាំងបីបាននាំគ្នាលុតជង្គង់សំពះថ្វាយបង្គំរូបសំណាក់តំណាងព្រះពុទ្ធ។ គ្នាបានឃើញរូបព្រះអង្គ គ្នាហាក់មានអារម្មណ៍ដូច ជាដឹងខ្លួន ហើយសួរខ្លួនឯងថាតើគ្នាកំពុងនៅទីណា? តើវាជាសុបិន្តឬក៏យ៉ាងណា? គ្នាកាន់តែគិតគ្នាកាន់តែឆ្ងល់ហើយកាន់តែភ័យនៅក្នុងចិត្តព្រោះតែគ្នាបានមកដល់ទីនេះយូរណាស់ហើយ ម្យ៉ាងគ្នាដូចជាមិនបានជួបអ្នកដែលគ្នាស្គាល់ម្នាក់សោះ តើពួកគេនៅទីណា? ពេលនោះហើយ ដែលគ្នាលែងសប្បាយ បេះដូងរបស់គ្នាបានលោតខុសចង្វាក់ តែគ្នាមិនបានបង្ហាញឲបុទមវត្តី ដឹងនោះទេ គ្នាធ្វើហាក់បីដូចជាធម្មតា។

រួចរាល់ពីការសំពះហើយ ទើបពួកយើងចេញមកក្រៅដើម្បីមើលទេសភាពបន្តនៅលើកោះ។ បីនាក់យើងបានដើរពីកន្លែងមួយទៅកន្លែងមួយ ដោយបុទមវត្តីនិយាយមិនចេះអស់ពាក្យលើកលែងតែគ្នាប៉ុណ្ណោះដែលបន្ថយការនិយាយស្តី។

ពួកយើងបានដើរមើលជុំវិញកោះដូចជាអ្នកដ៏ទៃទៀតដែរ។ គ្នាបានគិតថាបើសិនបានរស់នៅលើកោះនេះវិញមិនដឹងថាសប្បាយយ៉ាងណានោះទេ ព្រោះនៅទីនេះពិតជាប្លែកជាងកោះដទៃដែលគ្នាបានឃើញនិងបានទៅលេង។

ក្រោយពីបានដើរលេងអស់ចិត្តហើយ ទើបពួកគ្នាទាំងបីនាក់នាំគ្នាឡើងមកលើកប៉ាល់ដ៏ធំស្កឹមស្កៃរបស់ពួកយើងវិញ។ គ្នាអស់អារម្មណ៍ហើយនៅពេលនោះ គ្នាកាន់តែគិត គ្នាកាន់តែឆ្ងល់ហើយព្យាយាមរំលឹកថាគ្នាបានស្គាល់បុទមវត្តីតាមរបៀបណា? រឿងអីហេតុអីបានជាគ្នាបានមកដល់ទីនេះ? ហើយគ្នាអាចទិញរបស់របរនិងចេះបើកកប៉ាល់យ៉ាងម៉េចទៅកើតបើគ្នាមិនទាំងធ្លាប់ចូលសាលារៀនបើកបរផង? ការគិតទាំងនោះហាក់គ្មានប្រយោជន៍ទាល់តែសោះព្រោះគ្នាបានបាត់បង់អស់ទៅហើយនូវការចងចាំទាំងប៉ុន្មាន។ គ្នាកាន់តែភ័យហើយនិងញ័រដៃញ័រជើង

ខុសពីធម្មតា។ ពេលដែលគ្នាឡើងមកលើកប៉ាល់វិញ គ្នាមើលទៅទីផ្ទាកប៉ាល់គ្មានមនុស្សម្នាក់សោះ មានតែបីនាក់គ្នា។ គ្នាបានសំលឹងមើលមុខបុទមវត្តីទាំងស្ងួត តែពួកគេនៅតែញញឹមមករកគ្នាដូចជាធម្មតា ហាក់បីដូចជាគ្មានរឿងអ្វីកើតឡើង។ ទោះយ៉ាងណាកប៉ាល់បានចេញពីកោះដ៏តូចនោះ ហើយគ្នាបានព្យាយាមនិយាយរំងាប់ចិត្តខ្លួនឯងថា គ្មានអ្វីកើតឡើងនោះទេ វាគ្រាន់តែការសុបិន្តតែប៉ុណ្ណោះ។ កប៉ាល់បានបន្តល្បឿនយ៉ាងលឿនចេញពីកោះ ហើយនៅពេលដែលវាមានលំនឹងមិនឃ្លីងឃ្លោងហើយ គ្នាបានសួរអ្នកទាំងពីទាំងទឹកមុខស្ងួតថា៖

**«បុទមវត្តីចង់ទៅណាទៀតទេ?»**

នាងទាំងពីរនៅស្ងៀមដោយមើលមុខគ្នាទៅវិញទៅមក ហាក់បានឆ្ងល់ថាហេតុអ្វីបាន ជាគ្នាផ្លាស់ប្តូរសំលេងនិងកាយវិការដូចនេះ។ នាងមិនឆ្លើយតែគ្នាបានសួរបញ្ជាក់ទៅទៀតថា៖

**«តើពួកនាងចង់ទៅណាទៀត ពួកនាងមិនលឺខ្ញុំសួរទេអី?»**

**«បងបានដឹងរឿងដែលបានកើតឡើងហើយមែនទេ?»** បុទមសួរដោយក្លាហាន

**«ដឹងរឿងអី?»** គ្នាសួរបញ្ជាក់

បុទមបែបភ្ញាក់នៅពេលដែលបានសួរសំនួរខុសនេះ ក្នុងសភាពប្រថុចញុចនោះវត្តីបែរជាបន្លឺសួរបង្វែរឡើងថា៖

**«បុទមគេចង់សួរថា បងបានដឹងថាពួកយើងត្រូវទៅទីណាទៀតមែនទេ?»**

គ្នាក្រវីក្បាលមិនទទួលយល់ព្រម ឯវត្តីបានបន្តការបង្វែរទៀតថា៖

**«បង ខ្ញុំចង់ទៅលេងកោះនោះណាស់»** នាងបានលើកដៃចង្អុលទៅម្ខាង

ជាការពិតចាន់ណារិន នៅពេលនោះ គ្នាហាក់បីដូចជាដឹងខ្លួនថាទាំងនេះមិនមែនជាសុបិន្តនោះទេ ហើយប្រហែលជាមានអ្វីដែលបានកើតឡើងចំពោះគ្នាមិនខាន។ គ្នាភ័យណាស់ តែគ្នាខំប្រមូលអារម្មណ៍ហើយនិយាយតបថា៖

**«មិនអីទេទៅក៏បានដែរ តែពួកអ្នកត្រូវប្រាប់ខ្ញុំថាខ្ញុំកំពុងនៅទីណា? ហើយមានរឿងអ្វីដែលបានកើតឡើងចំពោះខ្ញុំ?»**

គ្នានិយាយបណ្តើរមើលទៅផ្លូវសមុទ្រខាងមុខបណ្តើរ ដោយមិនមើលទៅពួកនាងនោះទេ។





អ្នកទាំងពីរនៅស្ងៀម ហើយគ្នាដឹងថាពួកនាងបានប្រែទឹកមុខពីការសប្បាយមកជាស្រពោនទាំងពីរនាក់ទៅវិញ។

ដោយនាងមិនព្រមឆ្លើយដូចនេះគ្នាបានអង្វរទៅម្តងទៀតថា៖

**«ប្រាប់ខ្ញុំមកថាខ្ញុំមានរឿងអី ខ្ញុំសូមអង្វរ!»**

នាងនៅតែមិនឆ្លើយដដែលធ្វើឲគ្នាទៅជាមានកំហឹងយ៉ាងខ្លាំងគ្នាបានស្រែកគំហកខ្លាំងៗថា៖

**«ប្រាប់មិនប្រាប់?»**

លឺដូចនេះបុទមបែរទៅជាយំសោកសៅ ស្រក់ទឹកភ្នែកមួយរំពេច តែគេនៅតែមិនឆ្លើយដដែល ពួកគេអោនមុខចុះជាមួយនិងស្បៃដ៏សក្បុសរបស់គេ។ ឃើញពួកនាងដូចនេះ គ្នាបានទៅអង្អែលក្បាលអ្នកទាំងពីរហើយនិយាយថ្នមៗមកវិញថា៖

**«ខ្ញុំសូមអង្វរណា! បើសិនជាពួកអ្នកស្រលាញ់និងអាណិតខ្ញុំ ហើយបើពួកអ្នកមកការពារនិងចង់ឲខ្ញុំមានសេចក្តីសុខ សូមប្រាប់ខ្ញុំមកថាមានរឿងអ្វីដែលកើតឡើងចំពោះខ្លួនខ្ញុំ?»**

បុទមកាន់តែទ្រហោយំកាន់តែខ្លាំង ឯវត្តីវិញនាងមានទឹកមុខស្រពោនហើយខំទៅជូតទឹកភ្នែកឲបុទមដែលជាបងស្រី រួចទើបបន្លឺថា៖

**«តាមពិតរូបបងបានស្លាប់ទៅហើយ!»**

នៅពេលដែលលឺដំបូង គ្នានៅមិនទាន់ជឿនៅឡើយនោះទេ។ គ្នាបានគិតថាទាំងនេះគ្រាន់តែពាក្យកុហកបោកប្រាស់ទាំងអស់។ គ្នាបានប្រមូលអារម្មណ៍និងខំប្រឹងដកដង្ហើមយ៉ាងធំដោយនៅតែគិតថាវាគឺជាការសុបិន្តតែប៉ុណ្ណោះហើយមិនប៉ុន្មានទៀតទេ គ្នានិងបានភ្ញាក់ដឹងខ្លួនមិនខាន។ ដោយនៅក្នុងចិត្តបានរំពឹងដូចនេះគ្នាបាន បានសួរបញ្ជាក់ទៅនាងម្តងទៀតថា៖

**« សុំទោសអំបាញ់មិញវត្តីនិយាយយ៉ាងម៉េច?»**

**«ខ្ញុំមិនកុហកបងទេ តាមពិតបងបានស្លាប់៤ថ្ងៃហើយ»**

វត្តីនិយាយបណ្តើរបង្ហាញទឹកមុខដ៏ស្រពាប់ស្រពោនរបស់នាងបណ្តើរ។

គ្នាដឹងនៅពេលដែលគ្នាបានស្តាប់ច្បាស់ក្នុងត្រចៀកកាលណាហើយបេះដូងរបស់គ្នាពេលនោះហាក់មានសន្ទុះខុសពីធម្មតា។ គ្នាពិតជាភ័យណាស់ ហើយដៃជើងគ្នាប៉ុន្មានចាប់ផ្តើមញ័រឡើងរណ្តំពេញខ្លួនប្រាណ។គ្នាខំដកដង្ហើមយ៉ាងធំមួយៗហើយប្រឹងសួរទៅនាងម្តងទៀតថា៖

«បើខ្ញុំស្លាប់ហេតុអ្វីបានជាខ្លួនខ្ញុំនៅជាមនុស្សនៅឡើយ? ហើយហេតុអ្វីខ្ញុំអាចមើលរូបរបស់ខ្ញុំបាន ម្យ៉ាងទៀតខ្ញុំមិនមានសំលៀកបំពាក់ដូចជាពួកនាង?»

«តាមពិតនេះមិនមែនរូបពីកំណើតរបស់បងនោះទេ វាគ្រាន់តែជាដួងព្រលឹងដែលកំពុងតែហោះហើរនៅក្នុងភពថ្មីនេះតែប៉ុណ្ណោះ ហើយនៅថ្ងៃទី៧នៃការស្លាប់របស់បង ទើបអ្វីៗនិងមានការផ្លាស់ប្តូរ មានន័យថាបងនិងមានសំលៀកបំពាក់ដូចជាខ្ញុំដែរ» វត្តីពោល

គ្នាគ្រវីក្បាលដោយនឹកក្នុងចិត្តថាគ្នាមិនជឿរឿងនេះជាដាច់ខាត ហើយនៅតែមានៈថាវាជាសុបិន្តចង្រៃតែប៉ុណ្ណោះ។ វត្តីបានឈប់យំបន្តិចតែនៅមានសំលេងខ្សឹកខ្សួលនៅឡើយ។ ពួកនាងទាំងពីរមើលមកគ្នាដោយសេចក្តីអាណិតនិងស្រលាញ់ជាទីបំផុត។

គ្នាមើលទៅពួកនាងដោយនៅតែគ្រវីក្បាលរហូត គ្នានៅតែមិនជឿហើយក៏លែងមានកំលាំងនិងចង់សួរសំនួរអ្វីទៅនាងទៀតដែរ។ អ្វីដែលគ្នាបានប៉ងនៅពេលនោះ គឺការបន់ស្រន់នៅក្នុងចិត្តឲគ្នាបានភ្ញាក់ដឹងខ្លួនមកវិញ ឲគ្នាបានរួចផុតអំពីរឿងនេះ។ វត្តីបានបន្លឺឡើងនៅពេលដែលឃើញគ្នាកំពុងតែមិនជឿនោះថា៖

«សូមបងកុំមានសេចក្តីសោកសៅធ្វើអ្វី ព្រោះពេលនេះបងបានមករស់នៅក្នុងសុខសន្តិភាព ហើយគ្មានការច្រណែនឈ្នានីស គ្មានគំនុំគុំគួន គ្មានមនុស្សអាក្រក់។ បងនិងមករស់នៅក្នុងភពមួយដែលគ្មានការគិតបារម្ភអ្វីទាំងអស់ បងនិងបានរស់នៅតែក្នុងភាពសុខដមរម្យនាតែប៉ុណ្ណោះ»

ពេលដែលនាងនិយាយចប់ត្រឹមនេះ គ្នាបែរទៅជាសើចព្រោះគ្នាដឹងថាម្នាក់ៗត្រូវតែស្លាប់គ្មានអ្នកណាជៀសផុតនោះទេ តែគ្នាពិតជាមិនទាន់ចង់ស្លាប់នៅពេលនេះឡើយ អ្វីដែលគ្នាបារម្ភជាងគេនោះគឺដានិតដែលជាអនាគតភរិយារបស់គ្នា ដែលពួកយើងនឹងត្រូវរៀបការនៅពេលដ៏ឆាប់ខាងមុខនេះ។ គ្នាសើចស្ងួតហើយប្រឹងគិតថាគ្នាបានស្លាប់យ៉ាងដូចម្តេច? តែអ្វីៗគ្នាពិតជាចាំមិនបានទាល់តែសោះ ទោះបីជាគ្នាខិតខំរំលឹកនៅក្នុងខួរក្បាលយ៉ាងណាក៏ដោយ។

គ្នាមិនអស់ចិត្តខំប្រឹងធ្មេចភ្នែក គ្រវីក្បាលតែគ្មានប្រយោជន៍នោះទេ នៅទីបំផុត គ្នាបានដាច់ចិត្តសួរទៅពួកនាងទាំងពីរដោយបេះដូងញ័រសួររណ្តំឡើងថា៖

«តើពួកនាងបានដឹងទេ ថាខ្ញុំបានស្លាប់យ៉ាងដូចម្តេច?»





«ជាការពិតណាស់ដែលបងមិនអាចចាំអ្វីទាំងអស់ក្រៅពីការសប្បាយ នោះប្រសិនបើពួកខ្ញុំមិនបង្ហើបប្រាប់ពីរឿងអតីតកាល» នាងឈប់បន្តិចហើយបន្តទៅទៀតថា៖

«បងនៅចាំទេ? នៅពេលដំបូងបំផុត ពេលដែលបងដឹងខ្លួនហើយពេលនោះបងបានឈរនៅចំចំនុចកណ្តាលនៃផ្ទាំងទិដ្ឋភាពពីរធំៗ មួយមានពណ៌សនិងមួយទៀតមានពណ៌ក្រហម។ ពណ៌ក្រហមគឺតំណាងឲរឿងរ៉ាវដែលកំពុងកើត ដែលពេលនោះបងបានឃើញយ៉ាងច្បាស់នូវ...»

នាងនិយាយមិនទាន់ចប់ផងគ្នាបាននិយាយកាត់ទៅនាងថា៖

«គ្រោះថ្នាក់ចរាចរមែនទេ?»

ពួកនាងងក់ក្បាលរួមគ្នាដោយចង់បញ្ជាក់ថាវាជាការពិត។ នៅពេលនោះហើយដែលគ្នាចាប់ផ្តើមមានការចងចាំឡើងវិញនូវអ្វីដែលបានកើតឡើងចំពោះរូបគ្នា។ តាមពិតទៅនៅយប់នោះគ្នានិងសារ៉េតបាននាំគ្នាជិះម៉ូតូទៅកាន់សាលាច្បាប់ម្តុំបឹងត្របែក ដើម្បីមើលឈ្មោះ មើលថ្នាក់រៀន ព្រោះគ្នាត្រូវចូលរៀននៅថ្ងៃបន្ទាប់ត្រូវជាថ្ងៃចន្ទ័។ គ្នានៅចាំបានទៀតថានៅ ពេលដែលគ្នាកំពុងតែជិះ ស្រាប់តែមេឃចង់ភ្លៀង ពួកយើងបានលឺសំលេងផ្គរលាន់យ៉ាងខ្លាំង។ ដោយមានសំលេងផ្គរខ្លាំងនិងមិនមានអាវភ្លៀងទុកទទូរផងនោះ ពួកយើងក៏បានបញ្ឆាម៉ូតូឲបកក្បាលត្រលប់មកវិញដោយមិនទាំងបានទៅមើលសាលាច្បាប់ផង។

កំពុងតែខំស្ទូតដំណើរដោយខ្លាចភ្លៀងធ្លាក់ស្រាប់តែពេលនោះមានឡានមួយមកកៀរពួកយើងទាំងពីរចំកណ្តាលម៉ូតូ។ ដោយកំលាំងកៀរបំបុកខ្លាំងពេក គ្នាមិនអាចទប់ដៃចង្កូតបានទេ នៅទីបំផុតពីរនាក់យើងបានដួលទៅម្ខាងលឺសូរ ប្រាវ....! ប្រាវ...,!

គ្នាមិនបានដឹងថាដួលបោកត្រូវអ្វីខ្លះ ឬម៉ូតូទៅទីណា ឬក៏ត្រូវទៅរកអ្នកបុកនោះដែរ។ នៅក្នុងអារម្មណ៍របស់គ្នាគឺមានតែសារ៉េត បារម្ភពីខ្លួនប្រាណរបស់គេមិនដឹងថាយ៉ាងម៉េចទៅហើយ។ សំរាប់គ្នាដូចជាមិនអីគ្នាដឹងខ្លួនហើយនៅចាំថាមានឡានកៀរពេលនោះ ហើយ គ្នាក៏ដូចជាមិនមានការឈឺចាប់អ្វីដែរ។ នៅក្រោយពីការបោកទៅលើថ្នល់ ដែលគ្នាមិនដឹងថាប៉ុន្មានវិនាទីនោះ គ្នាបានខំប្រឹងបើកភ្នែកទាំងលំបាកដោយខំប្រឹងសំលឹងទៅរកសារ៉េត។ គ្នាខំប្រឹងស្រវេស្រវាវារទៅរកសារ៉េតដែលពេលនោះគេនៅឆ្ងាយពីគ្នាប្រមាណជា៥ម៉ែត្រ។ គ្នាខំវារតតេះតតាស់ហើយស្រែកសួរទាំងខ្សាវៗថា៖

«ម៉េចហើយពួកម៉ាក?» ខ្ញុំមិនគិតថាគេបានលឺនោះទេ ព្រោះតែសំលេងអ៊ូអរនៅលើថ្នល់ម្យ៉ាងខ្ញុំហៅក៏មិនខ្លាំងដែរ។ ភ្នែករបស់ខ្ញុំស្ទើរតែបើកមិនរួចនោះទេ តែខ្ញុំខំប្រឹងសំលឹង ខណៈពេលដែលខ្ញុំដេកលើថ្នល់ដូចជាសារ៉េតដែរ ខ្ញុំបានឃើញទាំងព្រាវថាសារ៉េតបានដឹងខ្លួនហើយគេបានយកដៃមកស្ទាបក្បាលរបស់គេ។

កំពុងតែសំលឹង ទៅគេក្នុងអារម្មណ៍បាន ប្រសើរព្រោះគិតថាម្នាក់ៗអាចរួចផុតពីជីវិតនោះ ស្រាប់តែនៅពេលដំណាលគ្នា មានបុរសម្នាក់ មានមាឌធំល្មមបានដើរសំដៅមករកសារ៉េត។ ខ្ញុំមិនបានមើលមុខគេទេ ព្រោះតែអស់កំលាំង នៅក្នុងខ្លួនពេក ខ្ញុំគ្រាន់តែបានគិតថា ប្រហែលជាម្ចាស់រថយន្ត ដែលគេដឹងខ្លួនខុស ហើយ មកជួយមើលនិងបញ្ជូនពួកយើងទៅកាន់មន្ទីពេទ្យប៉ុណ្ណោះ។តែការគិតទាំងនោះវាបានខុសស្រឡះទាំងអស់។

បុរសចំលែកនោះ បានទាញដំបងឆក់ពណ៌ខ្មៅមួយ ហើយបានវាយសំពងទៅលើក្បាលសារ៉េតជាច្រើនដំបង។ ពេលដែលខ្ញុំឃើញបែបនេះ ខ្ញុំដែលពេលនោះកំពុងតែដេករាបនៅលើថ្នល់ បានខំប្រឹងប្រមូលកំលាំងងើបទៅលើ ទៅមើលមុខមនុស្សដែលកំពុងតែសំពងសារ៉េត។ ខ្ញុំងើយមើលវាទាំងភ្នែកមមើៗ ដោយទាំងនៅក្នុងខ្លួនវង្វេងវង្វាន់ដូចជាមនុស្សស្រវឹងស្រា។ជាការពិតថ្វីបើខ្ញុំស្ទើអស់ស្មារតីតែខ្ញុំបានឃើញច្បាស់ថាម្នាក់នោះវាធ្លាប់មានគំនុំជាមួយសារ៉េតតាំងតែពួកយើងនៅធ្វើការក្នុងសណ្ឋាគារជាមួយគ្នាម្ល៉េះ។

ហើយម្នាក់នោះក៏ធ្លាប់បានវាយ ជាមួយសារ៉េតនៅឯកន្លែងធ្វើការផងដែរ។ ខ្ញុំបានគិតនៅក្នុងចិត្តថាប្រហែលជាពេលនេះវានៅចងគុំនុំជាមួយនិងពួកយើងទៀត ទើបវាតាម ព្យាបាទ ពួកយើងដូចនេះ។ ខ្ញុំប្រាប់ ចាន់ណារិនឯងតាមត្រង់ នៅពេលដែលខ្ញុំឃើញគេវាយសារ៉េតយ៉ាងដំណំយ៉ាងនេះ ខ្ញុំពិតជា មានការឈឺចាប់យ៉ាងខ្លាំងនៅពេញបេះដូង តែខ្ញុំមិនដឹងថាត្រូវទៅជួយយ៉ាងម៉េច ព្រោះខ្ញុំស្ទើរ តែបើកភ្នែកមិនទាំងរួចផង។ ខ្ញុំគ្រាន់តែខំប្រមូលកំលាំងលើកដៃទាំងរវិករវក់ហើយចង្អុលទៅមនុស្សនោះថា៖

«អាថៃ ឈប់វាយ!.......»

គ្រាន់តែលឺសំលេងរបស់ខ្ញុំភ្លាម វាបានក្រលេកមករកខ្ញុំរួចដើរសំដៅមកចាប់គ្របួចសក់របស់ខ្ញុំយ៉ាងពេញទំហឹងដៃរបស់វា ហើយបានវាយខ្ញុំនិងដំបងរបស់វាដោយស្រែកយ៉ាងខ្លាំង





ទៀតថា៖

«ម្អែងកុំចេះ!»

មនុស្សចិត្តអន្ធេរត្ថិយ្យបានចាប់វាយកញ្ចឹងកខ្ញុំយ៉ាងពេញទំហឹង វាវាយខ្ញុំហើយវាយទៀត វាយយកតែមួយឈ្នះដៃ។ ទោះបីជាកំលាំងដៃនិងទំងន់ដំបងធ្ងន់យ៉ាងណាក៏ដោយ តែពេលនោះខ្ញុំហាក់មិនមានអារម្មណ៍ឈឺអ្វីទាំងអស់ខ្លួនប្រាណរបស់ខ្ញុំហាក់បីដូចជាស្លឹកស្រពន់ណាស់ទៅហើយ។ ខ្ញុំនៅនឹងមួយកន្លែងដោយមិនមានមាត់កនិងតដៃអ្វីទាំងអស់ ខ្ញុំទុកឱវាវាយ សំពងនៅត្រង់ក្បាល កញ្ចឹងកនិងខ្នងទៅតាមចិត្តខឹងនិងកំលាំងរបស់វា។ យ៉ាងណា ខ្ញុំហាក់មានអារម្មណ៍សប្បាយទៅវិញព្រោះដឹងថាពេលណាដែលវាជាប់ដៃវាយខ្ញុំដូចនេះ សារ៉េតនិងបានធូស្រាលនឹងរួចខ្លួនមិនខាន ព្រោះតែខ្ញុំគិតដល់ប្រពន្ធនិងកូនសារ៉េត តើពួកគេនឹងកើតទុក្ខយ៉ាងណានៅពេលដែលសារ៉េតឈឺ? ខ្ញុំសុខចិត្តឈឺខ្លួនឯងចុះប្រសើរជាង។ តែអារម្មណ៍ទាំងនេះបានរលត់ទៅវិញនៅប៉ុន្មានដំបងចុងក្រោយរបស់វា ដែលវាយចំយ៉ាងធ្ងន់នៅពីលើក្បាលនៃផ្នែកខាងក្រោយ។ ពីពេលនោះហើយដែលខ្ញុំមិនបានដឹងតទៅទៀតថាវាបានវាយខ្ញុំយ៉ាងណា ហើយខ្ញុំក៏មិនបានដឹងពីអ្វីទាំងអស់។ វិញ្ញាណរបស់ ខ្ញុំបានរលត់ផុតទៅទាំងនៅតែបារម្ភពីសុវត្ថិភាពរបស់សារ៉េតជាដរាប។

ខ្ញុំនៅចាំបានទៀតថា ឥចឹងហើយបានជាខ្ញុំចេះតែឆ្ងល់ថា ហេតុអ្វីបានជាខ្ញុំភ្ញាក់មកឈរនៅចំចំណុចកណ្តាលនៃផ្ទាំងពណ៌សនិងពណ៌ក្រហមនោះទៅវិញ? ហើយហេតុអ្វីបានជាខ្ញុំបានឃើញក្នុងផ្ទាំងក្រហមនោះ នូវហ្វូងមនុស្សម្នាដែលកំពុងតែមើលគ្រោះថ្នាក់នៅលើថ្នល់ មានសារ៉េតដែលត្រូវបានគេសែងដាក់ឡានពេទ្យជាដើម។

សំរាប់អ្នករបួសទីពីរដែលគេសែងដាក់ឡានពេទ្យ ហើយដែលខ្ញុំធ្លាប់គិតថាធ្លាប់ស្គាល់គេនោះតាមពិតទៅគេគឺជារូបខ្ញុំ រូបខ្ញុំដែលបានស្លាប់ដោយសារដំបងដ៏ឃោឃៅរបស់ឃាតករ។ នៅពេលដែលការចងចាំទាំងប៉ុន្មានបានមកដល់ក្នុងខួរក្បាលរបស់ខ្ញុំវិញ ចាន់ណារិនអើយពេលនោះហើយដែលខ្ញុំមិនអាចទប់ទឹកភ្នែកនិងការស្រែកទ្រហោយំនោះបាន។ខ្ញុំយំ ខ្ញុំស្រែករកអ្នកម្តាយ ខ្ញុំសុំឲគាត់ជួយខ្ញុំផងតែគាត់មិនបានលឺខ្ញុំនោះទេ។ វាគឺជាពេលដែលខ្ញុំសោកស្តាយរកអ្វីមកប្រៀបពុំបាននោះទេ។ ខ្ញុំពុំដែលនឹងស្មានទាល់តែសោះថាខ្ញុំគួរតែស្លាប់ដូចនេះ

ទេ។គ្នាយំមិនចេញតែទឹកភ្នែករបស់គ្នាបានហូរហាមហូរព្រោះតែស្រណោះនូវអ្វីៗគ្រប់យ៉ាង។ គ្នាស្រែកយំហើយដើរទៅកាន់ចិរឹងដែកខាងមុខកប៉ាល់តែម្នាក់ឯង បុទមវត្តីពេលដែលឃើញគ្នាដូចនេះ ពួកនាងមិនបាននិយាយអ្វីទាំងអស់ ក្រៅពីសំលឹងមករកគ្នាទាំងទឹកមុខដ៏ស្រពាប់ស្រពោន។គ្នាមើលទៅទឹកសមុទ្រហើយខំបន្តការចងចាំទៀត។

គ្នានៅចាំនៅថ្ងៃចុងក្រោយ ថ្ងៃដែលគ្នាស្លាប់នោះគឺត្រូវជាថ្ងៃទី១២ខែតុលាឆ្នាំ២០០៣។ នៅព្រឹកនោះ នៅពេលដែលគ្នាភ្ញាក់ពីដំណេកឡើង ម៉ោងប្រមាណជា០៧ព្រឹក គ្នាបានជូន អ្នកម្ដាយរបស់គ្នាទៅចំការនៅឯកៀនស្វាយ។ នៅថ្ងៃនោះគ្នាហាក់បានដឹងខ្លួនជាមុន ហើយបាន និយាយនូវពាក្យចំលែកៗទៅកាន់រូបគាត់រហូតដល់ពេលខ្លះគាត់បានស្ដីឲគ្នា ដោយមិនចង់ឲគ្នា និយាយពាក្យអ្វីដែលជារឿងអពមង្គល។ ព្រឹកនោះគ្នាមិនដឹងទាល់តែសោះ នៅពេលដែលធ្វើដំណើរជាមួយអ្នកម្ដាយដែលគ្រប់ពេលជូនគាត់ទៅ គ្នាមិនសូវជានិយាយស្ដីទេ តែពេលនោះគ្នាទៅជាចូលចិត្តនិយាយលេងសើចជាមួយគាត់ទៅវិញ។ គ្នានិយាយជាមួយគាត់ហាក់បីដូចជាកូនក្មេងដែលចូលចិត្តប្រលែងលេងនិងតុក្កតាឥចឹង។ ក្នុងការធ្វើដំណើរ គ្នានិយាយមិនឈប់ទាល់តែសោះទាំងទៅទាំងមក។ ហើយនៅពេលដែលគ្នានិងអ្នកម្ដាយត្រលប់មកវិញ ពួកយើងទាំងក្រុមគ្រួសារបាននាំគ្នាញ៉ាំបាយជុំគ្នារួមមានលោកអ្នកមានគុណទាំងពីរបងស្រីបងប្រុស និងប្អូនប្រុសរបស់គ្នាផង។នៅពេលញ៉ាំបាយជាលើកចុងក្រោយនោះវាពិតជាចំលែកជាងការញ៉ាំបាយលើកណាណាទាំងអស់។ នៅពេលនោះលោកទាំងពីរបានចាប់ផ្ដើមនិយាយពីអនាគតរបស់គ្នាពីបញ្ហារៀបការ រវាងគ្នានិងដានិតនៅពេលខាងមុខ ដែលពួកគាត់បានសន្យាថានឹងធ្វើឲបានល្អព្រោះវាជាមង្គលការទីមួយនៅក្នុងគ្រួសារ។ ជាលើកទីមួយហើយដែលគ្នាមានការរលីងរលោងទឹកភ្នែកនៅពេលដែលបានលឺពាក្យសំដីរបស់ពួកគាត់ទាំងនេះ។

ញ៉ាំបាយរួចរាល់ហើយ គ្នាបានមកអង្គុយមើលទូរទស្សន៍ខ្សែរកាបមួយភ្លែតមុននិងចូលទៅក្នុងបន្ទប់របស់គ្នាក្នុងបំណងចូលសំរាកមួយភ្លែត។ រំពេចនោះស្រាប់តែដានិតបានទូរស័ព្ទមកគ្នាបានលើកហើយបានដឹងថានាងចេញពីធ្វើការនៅម៉ោង៨យប់នោះ។





ដូចចាន់ណារិនដឹងរួចមកហើយ ស្ទើរតែរាល់ថ្ងៃទៅហើយដែល គ្នាត្រូវទៅទទួលនាងចេញពីកន្លែងធ្វើការយកទៅផ្ទះ។

ពួកម៉ាកឯងចាំទេ?ពីអ្វីដែលគ្នាបាននិយាយប្រាប់ថាគ្នាពិតជាអាណិតនិងស្រលាញ់ដានិតណាស់ហើយគ្នាបានគិតទៀតហើយថានៅពេលដែលរៀបការរួច គ្នានិងឲនាងឈប់ធ្វើការហើយ។ ដូចជាពួកម៉ាកឯងដឹងហើយថាគ្នាពិតជាចង់ឲនាងប្រកបរបរជាអ្នករកស៊ីប្រចាំគ្រួសារវិញ។ ការសន្ទនាជាមួយនាងនៅតាមទូរស័ព្ទនៅពេលនោះ គ្នាហាក់មានអារម្មណ៍កាន់តែអាណិតនាងនិងស្រលាញ់នាងជាទ្វេរឡើង។គ្នាពិតជាចង់ស្ទុះទៅជួបនាងហើយប្រាប់នាងថា៖

**«បងពិតជាស្រលាញ់អូនណាស់ហើយបងសូមសន្យាថា បងនិងជូនអ្វីដល់អូនគ្រប់យ៉ាងដែលបងមាន»។**

ក្រោយពីនិយាយចប់លើខ្សែរទូរស័ព្ទ គ្នាបានសំលឹងមកមើលទូរស័ព្ទរបស់គ្នា វាហាក់បីដូចជាបានបង្ហាញរូបរបស់នាងដែលកំពុងតែញញឹមមកគ្នា។ គ្នាបានដាក់ទូរស័ព្ទទៅម្ខាង ហើយមកអង្គុយលើតុដែលនៅទីនោះគ្នាបានមើលសៀវភៅនិង ប្រដាប់ប្រដារសិក្សាខ្លះដែលបានទិញទុកសំរាប់ការចូលរៀនមហាវិទ្យាល័យរបស់គ្នានៅថ្ងៃស្អែក។ គ្នាក៏បានឃើញកាតាបខ្មៅដែលគ្នាបានទិញជាមួយចាន់ណារិនឯងនៅឯផ្សារបឹងកេងកង។ ពេលដែលគ្នាបានឃើញវា វាបានធ្វើឲគ្នានឹកទៅដល់ចាន់ណារិនឯងភ្លាមព្រោះគ្នានៅចាំបានថាកាលដែលគ្នាទិញបានតំលៃថោក ក៏ព្រោះតែចាន់ណារិនឯង ដែលជាអ្នកតថ្លៃឲគ្នា។ គ្នាបានយកដៃមកអង្អែលថ្នមៗ លើកាតាបនោះ ហើយនឹកទៅដល់ពួកម៉ាកឯងម្ដងទៀតដោយមិនដឹងថាតើពេលណាពួកយើងមានសំណាងជួបគ្នាសារជាថ្មី។ ខណៈនោះ គ្នាហាក់ឃើញពេលវេលា វាពិតជាយូណាស់សំរាប់គ្នា។ គ្នាហាក់មានអារម្មណ៍កណ្ដោចកណ្ដែងតែម្នាក់ឯង ហើយគ្នារំពឹងគិតទៀតថា ប្រសិនបើចាន់ណារិនឯងបានដឹងថាគ្នាបានចូលរៀនច្បាប់នៅថ្ងៃស្អែកនោះ មិនដឹងថាសប្បាយចិត្តយ៉ាងណានោះទេព្រោះតែពួកម៉ាកឯងក៏ចូលចិត្តមុខជំនាញនេះណាស់ហើយក៏ចង់ឲគ្នាបានបន្តការសិក្សាបន្ថែមទៀតដែរ។ នាទីនោះវាក៏បានធ្វើឲគ្នារំភើបណាស់ដែរ កាលដែលគ្នាបានបោះបង់ការសិក្សាជាយូរណាស់មកហើយ ដើម្បីមកធ្វើការយកកំរៃមកទប់ទល់និងជីវភាពដោយជៀសវាងការពឹងផ្អែកទៅលើកំលាំងឳពុកម្ដាយ។ ពេលដែលគ្នានឹកឃើញពួកម៉ាកឯង ធ្វើឲគ្នាកាន់តែនឹក ឃើញ

អនុស្សាវរីយ៍ទាំងអស់ដែលពួកយើងបានសាងរួមគ្នា។ ខ្ញុំញញឹមដាក់កាបូបខ្មៅនោះ តែម្នាក់ឯងនៅក្នុងបន្ទប់ដែលបិទជិត។ រួចមកទើបខ្ញុំយកសៀវភៅនិងប្រដាប់ប្រដាសិក្សា ដាក់ចូលទៅក្នុងកាបូបខ្មៅធ្វើពីស្បែកនោះហើយខ្ញុំបានរុញវាទៅម្ខាងទៅជ្រុងតុរួចទើបខ្ញុំ
ដើបខ្លួនចេញពីកៅអី។ខ្ញុំបានដើរមកកាន់ទូរដាក់ខោអាវវិញម្តងដែលពេលនោះខ្ញុំបានសំលឹងទៅមើលពួកវា ហើយនឹកហួសចិត្តតែម្នាក់ឯងថា ហេតុអ្វីបានជាខ្ញុំទៅទិញខោអាវខ្លះ ដែលមានតំលៃរហូតដល់ទៅ២០ឬ៣០ដុល្លាដូចនេះ។ ខ្ញុំមិនយកមកក្រៅទេគ្រាន់តែខ្ញុំរែកមើលរបស់របរទាំងនោះដែលកំពុងតែព្យួរយ៉ាងមានសណ្តាប់ធ្នាប់បំផុត។ ខ្ញុំមើលពួកវាដោយគិតថា តាមពិត របស់របរទាំងនេះវាគ្មានអ្វីល្អសំរាប់ខ្ញុំទៀតនោះទេ។ ងាកចេញពីទូរដាក់សំលៀកបំពាក់ខ្ញុំតំរេតខ្លួននៅលើគ្រែហើយគេងមើលទៅដំបូលដោយ ចាប់ផ្តើមសំលឹងរូបថតពីឆ្វេងទៅស្តាំដែលមានព្យួរនៅតាមជញ្ជាំង។ ខ្ញុំសំលឹងមើលសន្សឹមៗ នៅពេលនោះខ្ញុំបានឃើញរូបថតក្រុមគ្រួសារបងប្អូនរបស់ខ្ញុំ ហើយពិសេសគឺមិត្តភក្តិទាំងឡាយដែលរូបទាំងអស់សុទ្ធតែខ្ញុំស្រលាញ់។ ខ្ញុំមើលបណ្តើរនឹកសើចបណ្តើរហើយគិតថា ពេលវេលាពិតជាទៅមុខឥតឈប់ឈរឡើយ។ ក្រលេកទៅមើលរូបនៅលើជញ្ជាំងរួចហើយ ទើបខ្ញុំត្រលប់មកមើលរូបថតគូរដណ្តឹងដ៏កំសត់របស់ខ្ញុំដែលបានដាក់តាំងលើតុកុក្កតាមួយនៅលើតុតូចក្បែគ្រែរបស់ខ្ញុំ។ ខ្ញុំបានលើករូបនោះយកមកមើលហើយបានយកដៃអាវមកជូតលើកញ្ចក់ថ្មមៗ។ ខ្ញុំបានថើបរូបរបស់ដានិតទាំងអារម្មណ៍មួយដ៏សែនអាល័យ រួចមក ទើបខ្ញុំលើកមកដាក់នៅលើដើមទ្រូង។ នៅពេលនោះ ខ្ញុំមិនដឹងថានឹងមានរឿងអ្វីកើតឡើងនោះទេ ខ្ញុំហាក់បីដូចជានៅតែម្នាក់ឯង គ្មានអ្នកណាដឹងលឺខ្ញុំបានថាគេងអោបរូបនាងរហូត ទាល់តែខ្ញុំគេងលក់មិនដឹងខ្លួនដោយខ្ញុំមិនបានដឹងថាគេងលក់អស់ពេលប៉ុន្មាននោះទេ តែនៅវេលាម៉ោងប្រមាណជា១៥៣០នាទីខ្ញុំបានក្រោកទាំងស្រែកឡើងថា៖

**«ដានិត! ដានិត!,....អូន»**

ខ្លួនប្រាណរបស់ខ្ញុំបានជោគជាំទៅដោយគ្រាប់ញើសធំៗ នៅពេញអាវយឺតក្នុងខ្លួនរបស់ខ្ញុំ ឯចំណែកបេះដូងខ្ញុំវិញក៏បានញ័រចំប្រប់ខុសពីធម្មតាដែរ។ ខ្ញុំមិនចាំទេថាខ្ញុំបានសុបិន្តឃើញអ្វីអំបាញ់មិញនោះ តែវាហាក់បីដូចជានៅក្នុងភពដ៏ខ្មៅងងឹតមួយដែលនៅក្នុងសុបិន្តនោះ មានអ្វី





ម្យ៉ាងបានចាប់ដានិតចេញពីទ្រូងរបស់ខ្ញុំ។ខ្ញុំភ័យណាស់និងបានស្រែករហូតទាល់តែភ្ញាក់យ៉ាងដូចនេះ។នៅពេលដែលខ្ញុំបានដឹងខ្លួនខ្ញុំបានខំស្ទុះងើបចេញពីគ្រែទាំងដៃនៅកាន់រូបថតរបស់នាងនៅលើទ្រូងរបស់ខ្ញុំ។ ខ្ញុំសំលឹងមើលរូបរបស់នាងម្តងទៀត រួចទើបដាក់ទៅលើតូនតុនៅលើក្បាលដំណេកវិញដោយនឹកមមៃឃើញថាប្រាកដជាមានរឿងអ្វីកើតឡើងមិនខាន។
ខ្ញុំបានងើបចេញពីគ្រែ ហើយសំដៅទៅងូតទឹកចេញឲបានស្រលះខ្លួន និងអាចបានរួចផុតពីសុបិន្តស្រពេចស្រពិលទាំងនេះ។ ងូតទឹករួចខ្ញុំបានមកប្តូរសំលៀកបំពាក់មកជាធម្មតាវិញ។ ថ្ងៃនេះជាថ្ងៃទី១២ពាក់កណ្តាលខែតុលាទៅហើយ នៅពេលនោះខ្ញុំក៏ចង់ទៅកន្លែងធ្វើការរដ្ឋដែរព្រោះបានគិតថាប្រហែលជាគេបើកលុយខែចាស់មិនខាន។ មុនពេលទាញម៉ូតូចេញពីផ្ទះខ្ញុំបានជួបប៉ារបស់ខ្ញុំ ដែលពេលនោះ គាត់កំពុងតែអង្គុយអានកាសែតនៅលើសាឡុង។ គាត់បានសំលឹងនិងសួរមកខ្ញុំថា៖

**«កូនកាទៅណា?»**

**«ទៅមើលកន្លែងធ្វើការបន្តិចប៉ា ក្រែងលោគេបើកលុយ»**

**«ហើយចេញទៅជិះម៉ូតូ ម៉េចក៏មិនពាក់មួកការពារទៅផង»**

**«អត់អីទេប៉ា ខ្ញុំទៅតែមួយភ្លែតតើ»**

ចប់សំដី ខ្ញុំបានចាកចេញមក។ ខ្ញុំជិះម៉ូតូនៅតាមផ្លូវ ហើយនៅពេលដែលខ្ញុំជិះឆ្លងថ្នល់នៅមុខរោងកុនលុច្ស នៅពេលនោះខ្ញុំបានជួបជាតា ជាសង្សាររបស់ពួកម៉ាកឯងពីចំងាយ។ នៅពេលនោះដែរ នាងក៏កំពុងតែជិះម៉ូតូជាមួយសុរិកាមិត្តភក្តិស្រីរបស់នាង។ នៅពេលដែលពួកយើងបានឃើញគ្នា ខ្ញុំមិនបានឈប់និយាយជាមួយនាងទេ ពួកយើងបានត្រឹមតែញញឹមពីចំងាយប៉ុណ្ណោះព្រោះជាតាគេក៏ប្រញាប់ដែរ។ នាងបានទៅផ្លូវរបស់នាង ឯខ្ញុំក៏បានមកដល់កន្លែងធ្វើការរបស់ខ្ញុំដែរ។ពេលមកដល់ភ្លាម ដូចជាពួកម៉ាកឯងដឹងពីទំលាប់របស់ខ្ញុំហើយខ្ញុំបាននិយាយលេងជាមួយអ្នករួមការងារ។ ម្នាក់ៗសើចសប្បាយនិងការកំប្លែងរបស់ខ្ញុំ។ នៅក្នុងការសន្ទនាពេលនោះ ពួកគេក៏បានបបួលខ្ញុំឲទៅបាយល្ងាចនៅយប់នោះដែរ តែខ្ញុំបានប្រកែកព្រោះតែត្រូវចូលរៀននៅថ្ងៃស្អែក ថ្ងៃច័ន្ទផង។
ដោយប្រាក់ខែរដ្ឋគេនៅមិនទាន់បើក ហើយក៏ល្ងាចទៅហើយទៀតនោះ ខ្ញុំក៏បានលាពួកគេ

ហើយដើរសំដៅមកយកម៉ូតូវិញ ដោយគិតទៀតថាទៅបបួលសារ៉េតទៅមើលឈ្មោះជាមួយគ្នានៅសាលាច្បាប់។ ពេលដែលគ្នាបានជិះម៉ូតូចេញនោះ គ្នាបានជួបជាតានិងសុរិការម្តងទៀត។ លើកនេះគ្នាបានបញ្ឈប់ម៉ូតូនិងបាននិយាយលេងជាមួយពួកនាង។ ជាតាបានប្រាប់មកគ្នាថា នាងទើបតែបាននិយាយជាមួយពួកម៉ាកឯង តាមទូរស័ព្ទកុំព្យូទ័រមួយសន្ទុះធំណាស់ទៅហើយ។ ពេលដែលនាងបាននិយាយបែបនេះ គ្នាមានការសប្បាយចិត្តណាស់ជាពិសេសនៅ ពេលបានដឹងថាពួកម៉ាកឯងមានសេចក្តីសុខទុក្ខជាធម្មតា។ ពួកម៉ាកឯងនៅចាំទេនៅវេលាថ្ងៃនោះ នៅពេលដែលគ្នា ជាតា សុរិកាកំពុងតែនិយាយគ្នា ស្រាប់តែពួកម៉ាកឯង បានទូរស័ព្ទមកជាតាម្តងទៀត។ ជាតា នាងមិនបានលើកដោយដៃនាងទេ តែនាងបានហុចទូរស័ព្ទយ៉ាងរហ័សឲមកគ្នា។

នៅពេលដែលគ្នានឹកដល់ការសន្ទនារវាងពីរនាក់យើងនៅពេលនោះ ទឹកភ្នែករបស់គ្នាកាន់តែហូររហាមដោយមិនដឹងខ្លួន។ គ្នាមិនដឹងត្រូវនិយាយប្រាប់ពួកម៉ាកឯងយ៉ាងម៉េចពីសេចក្តី វេទនាចិត្តរបស់គ្នានោះទេ នៅពេលដែលគ្នាបានដឹងខ្លួនថា បានលាលោកនេះទៅហើយ នៅពេលនោះហើយដែលគ្នាគ្មានចង់បាននិងប្រាថ្នាអ្វីទៀតឡើយ ក្រៅអំពីភាពស្រណោះស្រណោក នឹករលឹកដល់បងប្អូនញាតិមិត្តទាំងអស់នោះ។

ចាន់ណារិនឯងនៅចាំទេ? នៅពេលដែលពីរនាក់យើងបានសន្ទនាជាមួយគ្នាលើកចុងក្រោយនោះ? គ្នានៅចាំពេលដែលគ្នាលើកទូរស័ព្ទ គ្នាពិតជាសប្បាយនិងបាននិយាយកំប្លុកកំប្លែងទៅពួកម៉ាកឯងថា៖

**«ម៉េចហើយអ្វី!និយាយគ្នារាប់ម៉ោងហើយនៅមិនទាន់ឆ្អែតទៀតអី?»**

ចាន់ណារិនឯងសើចហើយសួរមកគ្នាវិញ៖

**«ពួកម៉ាកសុខសប្បាយទេ?»**

គ្នានៅចាំថាពេលនោះ ពួកម៉ាកឯងបានត្អូញត្អែរប្រាប់មកគ្នាថាមានការនឹករលឹកជាតាណាស់ ហើយគ្នាក៏បានប្រាប់ទៅពួកម៉ាកឯងវិញដែរថាកុំឲមានការនឹករលឹកខ្លាំងពេកព្រោះគង់តែបានជួបគ្នាទេ។ គ្នានិយាយបែបនេះតាមពិតទៅ គ្នាបានយល់ចិត្តពួកម៉ាឯងយ៉ាងច្បាស់ តែណ្តើយគ្នាគ្រាន់តែចង់លើកទឹកចិត្តពួកម៉ាកឯងតែប៉ុណ្ណោះ។





អ្វីដែលគ្នានៅចាំជាងគេ គឺនៅពេលដែលពួកម៉ាកឯងបានសួរអំពីពេលវេលាដែលគ្នាត្រូវរៀបការ។ ជាការពិតនៅពេលនោះដែរ គ្នាបានឆ្លើយទៅពួកម៉ាកឯងវិញដោយអស់សង្ឃឹមព្រោះតែការទស្សន៍ទាយថាថ្ងៃខែមិនល្អ ពោលគឺឆុងនិងគ្នា ដូចជាពាក្យដែលចាស់ៗធ្លាប់និយាយ។ គ្នាមិនដឹងទេនៅពេលដែលគ្នានិយាយជាមួយពួកម៉ាកឯងនៅពេលនោះ វាហាក់បីដូចជាមានអ្វីម្យ៉ាងមករុញមាត់របស់គ្នាឲរអិលហើយនិយាយដោយមិនបានគិត វាហាក់បីដូចជាចង់ប្រាប់ទៅពួកម៉ាកឯងថាការនិយាយគ្នាលើកនោះ វាប្រហែលជាលើកចុងក្រោយហើយមើលទៅ។

គ្នាពិតជាសោកស្តាយថាវាមិនសមណាជាការសន្ទនាចុងក្រោយសំរាប់ពួកយើងទាល់តែសោះ។ នៅពេលដែលសន្ទនាជាមួយម៉ាកពួកឯងនោះ គ្នាក៏មានការចំលែកនៅក្នុងចិត្តណាស់ដែរ ព្រោះរយៈពេលពីរឆ្នាំមកហើយដែលពួកម៉ាកឯងបានចេញទៅរៀននៅឯបរទេស ហើយពួកយើងក៏មិនដែលបាននិយាយឲបានយូរឬសប្បាយដូចនេះដែរ។ មានតែពេលនោះប៉ុណ្ណោះដែលពួកយើង និយាយគ្នារហូតដល់ប្រមាណជា២០នាទី។ គ្រប់វិនាទីគ្នាចេះតែខ្លាចចិត្តពួកម៉ាកឯងព្រោះមិនចង់ឲពួកម៉ាកឯងបង់លុយច្រើនសំរាប់ទូរស័ព្ទ តែដោយសារតែការនឹករលឹក ពួកម៉ាកឯងខ្លាំងពេកនៅពេលនោះ គ្នាក៏ចេះតែបន្តការនិយាយជាមួយពួកម៉ាកឯង ជាហូរហែរបន្តទៅទៀត។

ពួកម៉ាកឯងនៅមានចាំទៀតទេ? កាលនោះយើងពិតជាបាននិយាយរឿងកំប្លែងជាច្រើន។ ពួកយើងបានចំអន់គ្នាទៅវិញទៅមកដោយថានឹងមិនមានកូនប្រើជាដើម បើពួកយើងមិនប្រញាប់រៀបការនោះទេ។ មែនហើយដែលការសប្បាយរបស់ពួកយើងនៅពេលនោះ វាគឺជា លើកចុងក្រោយបង្អស់សំរាប់សំលាញ់ទាំងពីរយើង។

ចប់ការសន្ទនាជាមួយពួកម៉ាកឯង គ្នាបាននិយាយរឿងដែលចាន់ណារិនឯងចង់ឲគ្នានាំស្រីៗទៅញាំគុយទាវនៅឯហាងបុរីថ្មីឲបានមួយខែម្តងគឺដើម្បីឲពួកយើងពុំស្ងួតគិតពីពេលវេលាពោលយើងចង់ឲពេលវេលាដើរឆាប់ទៅតាមទំលាប់មួយដែលយើងចង់ធ្វើជាប្រចាំខែ។

គ្នាបាននិយាយសុំទោសទៅជាតានៅពេលនោះដែរ ដែលគ្នាមិនបាននាំនាងទៅរហូតមកដល់ថ្ងៃ១២ពាក់កណ្តាលខែទៅហើយ។ ជាការពិតដែលគ្នាបានប្រាប់នាងថាគ្នាទើបតែមកពីខេត្ត

បាត់ដំបង បំពេញការងារនៅទីនោះ ដូចនេះហើយទើបគ្នាមិនមានពេលនិងបានជូននាងទៅ។ ទោះយ៉ាងណា គ្នាបានបបួលជាតា សុរិកា ទៅញ៉ាំអាហារល្ងាចនៅពេលនោះ តែពួកនាងបានប្រកែកដោយចង់លើកទៅពេលក្រោយវិញ ព្រោះនៅថ្ងៃនោះពួកនាងមិនស្រួលខ្លួន។ ចប់ការសន្ទនាបានបន្តិចទើបពួកយើងទាំងបីនាក់បានបែកផ្លូវគ្នារៀងៗខ្លួនមក។

ពេលដែលរំលឹកខ្លួនគ្នាដល់ត្រឹមនេះ ទឹកភ្នែកគ្នាបានហូរធ្លាក់សារជាថ្មី។ នៅពេលនោះហើយដែលគ្នាមិនអាចទ្រាំការទ្រហោយំបានទោះបើនៅមុខបុទមវត្តីក៏ដោយ។ពួកនាងទាំងពីរបានដើរមកជិតគ្នាហើយយកដៃមកអង្អែលស្មាររបស់គ្នាថ្នមៗព្រមទាំងសំលេងខ្សោយៗថា៖

**«ពួកខ្ញុំដឹងនិងយល់ពីអ្វីដែលបងកំពុងមានការឈឺចាប់នៅពេលដែលបានយល់ដឹងពីការពិតទាំងនេះ តែអូនសូមឲបងកាត់ចិត្ត ព្រោះតែម្នាក់ៗមានសង្ខារមិនទៀងឡើយ»**

ពេលដែលបានលឺពាក្យទាំងនេះពីនាង គ្នាបានយកដៃមកខ្ទប់មុខ និងបន្តការទ្រហោយំនិងរៀបរាប់ថា៖

**«តើពួកនាងស្គាល់ណារិននិងជាតាដែរឬទេ?»**

នាងទាំងពីរនៅស្ងៀមឯគ្នាបានបន្តទៅទៀតទាំងទឹកភ្នែកថា៖

**«ពួកគេទាំងពីរជាគូរសង្សារនិងគ្នា ហើយបានស្រលាញ់គ្នានៅពេលប្រហាក់ប្រហែលដែលខ្ញុំស្រលាញ់ដានិតដែរ។ ពួកយើងបានស្គាល់គ្នាជាច្រើនឆ្នាំណាស់មកហើយតាំងពីឆ្នាំ៩៦មកម្លេះពីពេលដែលយើងបានធ្វើការរួមគ្នានៅឯសណ្ឋាគារអាំងទែ។ ថ្វីត្បិតតែពួកយើងមិនមានអាយុដូចគ្នាក៏ដោយតែពួកយើងទាំងបួនស្រលាញ់គ្នាណាស់ ពួកយើងហាក់បីដូចជារលកបួនក្បាលដែលតែងតែហោះហើរទៅណាមកណាជាមួយគ្នារហូត។ពួកយើងមិនដែលភ្លេចពាក្យសន្យាថានឹងរៀបការជាមួយគ្នាម្តងណាឡើយតែក្តីសង្ឃឹមទាំងនេះបានរលាយអស់ទៅហើយ.... គឺនៅពេលដែលមានព្រានសាម៉ានមកប្រហាររលកមួយចេញពីហ្វូង តើរលកទាំងបីទៀត ពួកគេនិងមានការឈឺចាប់យ៉ាងណាទៅ???»**

គ្នាបាននិយាយទៅពួកគេបណ្តើរជាមួយនិងភាពខ្សឹកខ្សួលបណ្តើរ។ បុទម នាងមិនយំដូចជាគ្នាទេ នាងគ្រាន់តែមានទឹកមុខស្រងូតស្រងាត់ប៉ុណ្ណោះ។ តែសំរាប់វត្តី វិញ នាងបានស្រក់ទឹកភ្នែក





អាណិតមកលើរូបគ្នាដែរ។

ចាន់ណារិនអើយ នៅពេលនោះគ្នាពិតជាភ័យពិតជាខ្លាចហើយពិតជាសោកស្តាយនូវជីវិតរបស់គ្នាណាស់ ដោយហេតុនោះហើយទើបគ្នាយំតែរហូតទោះគ្នាបានដើរចេញពីពួកនាងមកក្រោយកប៉ាល់ដែលនៅចំកណ្តាលមហាសាគរដ៏ធំល្វឹងល្វើយនាភពថ្មីនោះក៏ដោយ។ គ្នាមកអង្គុយនៅខាងក្រោយតែម្នាក់ឯង គ្នាបានរំលឹកបន្តទៅទៀតនូវអ្វីដែលបានកើតឡើងក្នុងជីវិតអតីតរបស់គ្នា។ គ្នានៅចាំបានគឺនៅក្រោយពេលដែលគ្នាបានលាជាតានិងសុរិកា កាលពីថ្ងៃដែលគ្នានៅរស់នោះ គ្នាបានជិះម៉ូតូមកកាន់ផ្ទះសារ៉េតដែលនៅខាងក្រោយសាលាវិចិត្រសិល្បៈ។ ពេលមកដល់ដំបូងគ្នាបានជួបវ៉ាសនា ភរិយាសារ៉េត ដែលពេលនោះនាងរកចេញទៅផ្សារ។

**«សារ៉េតនៅផ្ទះទេ អាស្នា?»** គ្នាសួរ

**«គាត់នៅខាងក្នុងបងកា»** នាងនិយាយនិងគ្នាបណ្តើរហើយដើរចេញមកក្រៅទៅផ្សារបណ្តើរ។ គ្នាបានដើរចូលទៅខាងក្នុងផ្ទះដែលបានឃើញសារ៉េតកំពុងតែអានសៀវភៅ និងអង្គុយយោលអង្រឹងកូន។ ដូចជាពួកម៉ាកឯងដឹងហើយ នៅពេលដែលពួកយើងជួបគ្នាម្តងៗ ពួកយើងមិនដែលមានពាក្យ អ្វីត្រូវនិយាយឲកំសត់នោះទេ ពួកយើងចូលចិត្តណាស់និយាយលេងសើចដាក់គ្នា។ នៅពេលនោះគ្នាបានបបួលសារ៉េតមកសាលាច្បាប់ជាមួយនិងគ្នា មកមើលឈ្មោះចូលរៀនថានៅបន្ទប់និងថ្នាក់ណា។ សារ៉េតមិនបានប្រកែកទេ គេបានព្រមដោយទុកសៀវភៅចុះនិងទុកកូនឲទៅប្អូនស្រីគេមើលវិញម្តង។

ក្រោយពីបានរៀបចំខ្លួនរួចស្រេចហើយ ពួកយើងបានចេញដំណើរមកដែលពេលនោះម៉ោងប្រមាណជា១៩០០ទៅហើយ។គ្នាជាអ្នកឌុបឯសារ៉េតវិញជាអ្នកអង្គុយអោបចង្កេះគ្នាពីក្រោយ។ គ្នាបានប្រាប់ទៅសារ៉េតថាគ្នាបាននិយាយជាមួយចាន់ណារិនឯងអំបាញ់មិញ។ សារ៉េតគេក៏សប្បាយចិត្តណាស់ដែរនៅពេលដែលបានដឹងរឿងនេះ។ ពួកយើងនិយាយគ្នាជាប់មាត់រហូតនៅតាមផ្លូវ។ ពួកយើងបានបន្តជិះពីផ្ទះសារ៉េត តាមមហាវិថីព្រះមុនីវង្ស ដោយពេលនោះពួកយើងមិនបានដឹងថាមាននរណាតាមយើងពីក្រោយឡើយ។ ពេលដែលយើងជិះជិតទៅដល់សាលាច្បាប់ ស្រាប់តែពេលនោះយើងត្រូវបង្ខំចិត្តត្រលប់មកវិញ ព្រោះតែមេឃរកភ្លៀង។

កំពុងតែស្រូតធ្វើដំណើរត្រលប់មក ស្រាប់តែឃាតករដ៏សាហាវបានកៀរពួកយើងឲដួលទៅលើថ្មល់ ហើយបានចុះមកវាយក្នុងបំណងបំបាត់ជីវិតរបស់ពួកយើងទាំងពីរនៅក្នុងលេសចោទថាពួកយើងជាចោរទៅវិញ ដើម្បីបន្លំភ្នែកមហារជនហើយបន្តការវាយសំពងមកលើពួកយើងនៅពេលដែលពួកយើងបានបាត់បង់ស្មារតីក្រោយពីបានបោកក្បាលទៅនឹងថ្មល់។ ជាកុសលសារ៉េតបានរួចខ្លួន នៅសល់តែគ្នាដែលបានបាត់បង់ជីវិតដ៏សែនឈឺចាប់ដោយសារតែដំបងឆក់របស់ឃាតករ។

នៅពេលដែលគ្នាបានគិតពីអំពើដ៏ឃោរឃៅទាំងនេះរបស់ឃាតករដែលបានធ្វើមកលើគ្នានោះ កំហឹងរបស់គ្នាបានពុះកញ្ជ្រោល គ្នាបានខាំធ្មេញដោយនឹកនៅក្នុងចិត្តថាអាឃាតករនោះមិនអាចរួចខ្លួនឡើយ។ គ្នានឹងសងសឹកទៅតាមអ្វីដែលវាបានធ្វើមកលើគ្នាដោយអំពើរដ៏ឃោឃៅរបស់វានោះ។ ភ្លើងកំហឹងបានឆេះរោលពេញដើមទ្រូង។ គ្នាបានងើបឈរហើយដើរចេញសំដៅមកខាងក្រោយកប៉ាល់មកជួបជុំនិងបុទមវត្តីវិញដោយនិយាយទៅកាន់ពួកគេថា៖

**«តើពួកនាងអាចជួយឲខ្ញុំបានទៅលេងមិត្តភក្តិនិងក្រុមគ្រួសារខ្ញុំបានដែរឬទេ?»**

ពួកនាងទាំងពីរមើលមុខគ្នាទៅវិញទៅមក ឯវត្តីបានបន្លឺឡើង៖

**«ខ្ញុំដឹងថាបងកំពុងគិតអ្វីនិងចង់ធ្វើអ្វីចំពោះមនុស្សអាក្រក់ដែលបានសំលាប់បង តែពួកយើងគ្មានលទ្ធភាពនិងជួយបងឲចេញទៅធ្វើអ្វីបានទេមុនថ្ងៃទី៧នៃការស្លាប់របស់បង»**

នៅពេលដែលគ្នាបានលឺពាក្យសំដីទាំងនេះ វាបានធ្វើឲគ្នាកាន់តែអួលដើមក ណែនទ្រូងរកពាក្យអ្វីមកនិយាយឲសមក្រៅពីទឹកភ្នែកដែលនៅតែហូររហាម។ នេះជាលើកទីមួយហើយនៅក្នុងជីវិតរបស់គ្នាដែលគ្នាទទួលការក្រៀមក្រំយ៉ាងដូចនេះ។ ឃើញទឹកភ្នែកគ្នាកំពុងតែធ្លាក់មិនដាច់ វត្តីបានបែរមកនិយាយលួងលោមគ្នាវិញថា៖

**«សូមបងកុំកើតទុក្ខខ្លាំងពេក បើបងមានការនឹករលឹកមិត្តភក្តិនិងក្រុមគ្រួសារ បងអាចអញ្ជើញពួកគេមកទីនេះបានណា៎»**

គ្នាបានងើបមុខមើលទៅនាងហើយបានពោលទាំងទឹកភ្នែកទឹកសំបោរឡើងថា៖

**«បើខ្ញុំអាចអញ្ជើញពួកគេបានមកទីនេះចុះហេតុអ្វីបានជាខ្ញុំមិនអាចទៅជួបពួកគេដោយ**





**ផ្ទាល់?»**

បុទមតបដោយដកដង្ហើមធំ៖

**«វាជាក្រិតក្រមណាបង! ពួកយើងទាំងពីរមិនអាចធ្វើអ្វីឲលើសពីនេះបានទេ ពួកយើងគ្រាន់តែទទួលភារកិច្ចមកជួយតំរង់ទិសឲបងតែប៉ុណ្ណោះ»**

គ្នានៅស្ងៀមបន្តិច រួចមើលទៅមុខនាងទាំងពីរដែលកំពុងតែឈរសំលឹងមើលមកគ្នា ហើយគ្នាបាននិយាយទៅពួកនាងវិញថា៖

**«បើតចឹងល្អហើយខ្ញុំចង់ហៅមិត្តភក្តិរបស់ខ្ញុំទាំងអស់ដែលខ្ញុំស្គាល់ឲមកកាន់ទីនេះ»**

**«សូមបងកុំបារម្ភពួកគេនឹងមកដល់បន្តិចទៀតនេះ»** វត្តីនិយាយ

ចប់សំដីពួកគេទាំងពីរក៏រលាយខ្លួនបាត់ទៅ ទុកឲគ្នានៅអង្គុយតែម្នាក់ឯងយំម្នាក់ឯង។ គ្នាងើបឈរហើយដើរសំដៅទៅកាន់ក្បាលកប៉ាល់ម្តងទៀត គ្នាងាកសំលឹងទៅឯនាយសមុទ្រ គ្នាស្រក់ទឹកភ្នែករហូតចាន់ណារិនអ្លើយ។ គ្នាបានគិតទៅដល់គ្រប់គ្នា ទាំងគ្រួសារ ទាំងមិត្តភក្តិ ហើយពិសេសទៅទៀតនោះគឺគូរដណ្តឹងដ៏កំសត់របស់គ្នា។ តើពេលនេះនាងមានសេចក្តីទុក្ខសោកយ៉ាងណា? នៅពេលដែលដឹងថារូបគ្នាបានចាកចេញពីនាង ចាកចេញដែលគ្មានថ្ងៃណាបានត្រលប់ឡើយ។ គ្នាយកដៃមកច្រូងសក់ ដោយនៅតែមិនអស់ចិត្តថា គ្នាអស់ជីវិតនៅត្រឹមនេះសោះ។ ហើយនៅពេលដែលនឹកពីការស្លាប់របស់គ្នា កំហឹងទាំងប៉ុន្មានក៏កាន់តែក្តៅ។ គ្នាបានសន្យានៅក្នុងចិត្តនៅពេលនោះថា ទោះបើគ្នាចុះនរកជាន់ណាក៏ដោយ គ្នាមិនទុកឲអាឃាតករនោះរួចខ្លួនឡើយ។ វានឹងស្លាប់ដ៏យ៉ាងវេទនា ឲសមទៅអ្វីដែលវាបានធ្វើមកលើគ្នា។ ពួកម៉ាកឯងដឹងហើយ ចាប់តាំងពីពេលដែលយើងស្គាល់គ្នា យើងមិនដែលចេះទៅរករឿងនិងអ្នកណាម្តងឡើយ ពួកយើងតែងតែទ្រាំរហូត តែពេលនេះគ្នាមិនអាចទ្រាំបានទៀតទេ គ្នាមិនសុខចិត្តនៅស្ងៀមឡើយ។ គ្នាបានគិតនៅក្នុងចិត្ត ត្រូវតែសំលាប់វា សងសឹកវិញនៅពេលដែលគ្នាត្រូវបានគេដោះលែងចេញពីទីនេះ។ ពេលដែលគ្នាបានគិតពីឃាតករដែលអត់ពូជនេះ ជាពេលដែលគ្នាលែងគិតពីបុណ្យបាបអ្វីទៀតហើយ វាជារឿងក្រោយ ប្រសិនបើគ្នាបានរំសាយកំហឹង។ កំពុងនឹកគិតនៅក្នុងការចងអាឃាត គ្នាហាក់បានទទួលសំលេងពីក្រោយខ្នងមកថា៖

«បង! មិត្តភក្តិរបស់បងទាំងប៉ុន្មានបានមកដល់ហើយ ពួកគេកំពុងតែនៅខាងក្រោម នៅក្នុងជណ្តើរយន្តដែលពួកគេនឹងឡើងទៅជួបបងនៅជាន់ខាងលើនៅឯបន្ទប់ទទួលភ្ញៀវ»

«សូមបងអញ្ជើញទៅកាន់ទីនោះ! មួយទៀតបងត្រូវប្រយ័ត្ន រឿងបងជាការពិតតែសំរាប់ពួកគេ ពួកគេកំពុងតែនៅក្នុងសុបិន្តតែប៉ុណ្ណោះ» បុទមបន្ត

គ្រាន់តែបានលឺពាក្យទាំងនេះភ្លាម គ្នាពិតជាមានសេចក្តីរីករាយជាពន់ពេក គ្នាបាត់យំ គ្នាខំជូតទឹកភ្នែក គ្នាឈប់ខឹងអ្វីទាំងអស់ ហើយខំប្រឹងដើរសំដៅមកកាន់បន្ទប់ទទួលភ្ញៀវ។ ចាន់ណារិនឯងមាននៅចាំទេ? នៅពេលដែលពួកម៉ាកឯងយោល់សប្តិឃើញគ្នានៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៣ ដែលត្រូវជាថ្ងៃទី៤នៃការស្លាប់របស់គ្នា។ កាលនោះពេលដែលពួកម៉ាក ឯងកំពុងតែសុបិន្តគ្មាននាក់ណាម្នាក់បានដឹងថាគ្នាស្លាប់នោះទេ។ទាំងចាន់ណារិនឯងទាំងមិត្តភក្តិឯទៀតគ្រាន់តែបានឃើញនៅក្នុងយោល់សប្តិថា បានមកដល់កប៉ាល់របស់គ្នាដោយ ការនាំដំណើររបស់បុទមវត្តីតែប៉ុណ្ណោះ។ គ្នាចង់ប្រាប់ពួកម៉ាកឯងនៅពេលនេះថា តាមពិតទៅយោល់សប្តិរបស់ពួកម៉ាកឯងថ្ងៃនោះ វាគឺជាការពិតទាំងអស់។ ជាការពិតដែល គ្នាបានឲចាន់ណារិនឯងបានឃើញរូបនិងស្ថានភាពរស់នៅរបស់គ្នាក្រោយពេលស្លាប់។

នៅចាំទេ?នៅពេលដែលពួកម៉ាកឯងនិងមិត្តភក្តិឯទៀតបានចូលមកដល់បន្ទប់បាយ ហើយឃើញតែចាន់ណារិនឯងម្នាក់ប៉ុណ្ណោះដែលនិយាយច្រើនជាងគេ នៅក្នុងសុបិន្តនោះ គ្នាកើតទុក្ខប៉ុនភ្នំតែពួកម៉ាកឯងបែរជានិយាយសើចៗតែរហូត។ កាលនោះគ្នាមិនបាននិយាយ តបទៅពួកម៉ាកឯងដូចពីមុននោះទេ ព្រោះតែគ្នាចង់អង្គុយនៅស្ងៀម មើលតែមុខដានិតដែលកំពុងតែស្រពាប់ស្រពោន។ គ្នាពិតជាចង់ទៅអោបថ្នាក់ថ្នមនាងណាស់តែពេលនោះ គ្នាពុំអាចធ្វើអ្វីបានឡើយ។ នៅក្នុងសុបិន្តនោះទៀត ម្នាក់ៗមានការសប្បាយរីករាយស្មើរតែគ្រប់គ្នានៅពេលដែលបានមកលេងនៅលើកប៉ាល់របស់គ្នា។

នៅពេលដែលគ្នាកំពុងតែខំប្រឹងសំលឹងមុខដានិតនោះ ស្រាប់តែបុទមវត្តីបានមកឳ្យប្រាប់គ្នាថា៖

«ដល់វេលាដែលពួកគេត្រូវត្រលប់ទៅវិញហើយបង ព្រោះពួកគេត្រូវភ្ញាក់ពីដំណេកនៅឯឋានមនុស្សលោក។» នាងបានបន្តទៀតថា៖





«សូមបងផ្តែផ្តាំពួកគេឲហើយទៅ ព្រោះបងអាចអញ្ជើញពួកគេមកទីនេះបានតែម្តងទេ រហូតដល់ថ្ងៃទី៧ទើបបងអាចទៅជួបពួកគេបានម្តងទៀត»

នៅពេលដែលគ្នាកំពុងតែស្តាប់អ្នកទាំងពីរដោយយកចិត្តទុកដាក់នោះស្រាប់តែចាន់ណារិនឯងបានស្រែកមកសួរគ្នាជាភាសារអង់គ្លេសពីជ្រុងតុម្ខាងថា៖

«ហេតុអ្វីបានជាពួកម៉ាកក្រៀមក្រំម្លេះ?»

គ្នាដឹងនៅពេលដែលចាន់ណារិនឯងបានយល់សប្តិឃើញគ្នានៅលើកដំបូងពួកម៉ាកឯងមិនបានដឹងថាគ្នាស្លាប់នោះទេ គ្នាមិនមាត់នឹងពួកម៉ាកឯងអ្វីទេ គ្នានៅស្ងៀម ខំប្រឹងតែសំលឹង ទៅមុខដានិត តែពេលនោះគ្នាក៏បានផ្ញើរសារតាមចិត្តថាគ្នាបានស្លាប់បាត់ទៅហើយ។ គ្នាដឹងនៅពេលដែលម្នាក់ៗបានដឹងជ្រាបពីដំណឹងនេះ ទាំងអស់គ្នាមានសេចក្តីក្រៀមក្រំយ៉ាងខ្លាំង តែធ្វើម៉េចពួកម៉ាកហើយ បើពួកយើងមាននិស្ស័យបានតែត្រឹមហ្នឹងនោះ។

ក្រោយពីបានផ្ញើរសារតាមចិត្តរួចរាល់ហើយ បុទមនិងវត្តីបានជូនអ្នកទាំងអស់គ្នាព្រមទាំងពួកម៉ាកឯងត្រលប់មកកន្លែងដើមរៀងៗខ្លួនវិញ។

ដឹងទេ? នៅពេលដែលមិត្តភក្តិនិងចាន់ណារិនឯងចុះពីលើកប៉ាល់ ហើយសួរកគ្នាដោយមិនឃើញគ្នាទៅជាមួយផងនោះ តាមពិតទៅគ្នាបានលឺពាក្យសួរកទាំងនេះ តែគ្នាមិនអាចទៅបានទេ គ្នានៅឈរលើកប៉ាល់ ប្រឹងសំលឹងមកពួកម៉ាកឯងដែលកំពុងតែចាកចេញ ទៅទាំងទឹកភ្នែកហូររហាម។ នៅពេលនោះគ្នាបានសំលឹងមើលបុទមវត្តីជូនអ្នកទាំងអស់គ្នា រហូតដល់ផុតកន្ទុយភ្នែក។ តើពួកម៉ាកឯងមាននៅចាំពីសុបិន្តមួយនេះឬទេ?

គ្នាសង្ឃឹមថាការរៀបរាប់នៅក្នុងសំបុត្រនេះនឹងអាចឲពួកម៉ាកឯងនៅចាំបានខ្លះមិនខាន។

ចាន់ណារិនអ្អើយ! ចាប់តាំងពីថ្ងៃទី៤រហូតដល់ថ្ងៃទី៧នៃការស្លាប់របស់គ្នា នៅចន្លោះ៣ ថ្ងៃនោះគ្នាយំរហូតគ្នាយំរហូតទាល់តែគ្នាហើមមុខហើមមាត់ហើមច្រមុះដែលមើលទៅវាមិនខុសពីសត្វជ្រូកដែលត្រូវទឹកក្តៅប៉ុន្មាននោះទេ។ អ្វីដែលធ្វើឲគ្នាកាន់តែខ្លោចចិត្ត គឺ នៅពេល ដែលបុទមវត្តីបានបង្ហាញពីទិដ្ឋភាពបុណ្យសពរបស់គ្នាដែលបានបារព្ធនៅឯវត្តឧណ្ណាលោម។ វាកាន់តែធ្វើឲ